**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ពន្ធលើចំណេញមូលធន

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ញ៉ី ប៉េងត្រី**

លោក **ដួង សុខហេង**

សាស្ត្រាចារ្យណែនាំ

លោក **ជ័យ រិទ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ញឹ ម៉េងគ្រី** និងខ្ញុំបាទឈ្មោះ **ដួង សុខហេង** យើងខ្ញុំទាំងពីរអ្នកជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២១ ដែលមានលេខកូដថ្នាក់L4C2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០១៧-២០២១ សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរពដឹងគុណនិងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖

លោកមានគុណទាំងបួនគឺលោកឪពុក **រៀល សុភ** និងអ្នកម្តាយ **ទាន ឆៃលៀក** វិញ្ញាណខ័ន្ធលោកឪពុក **ដួង សុធី** និងអ្នកម្តាយ **គឹម ចាន់រត្ថា** របស់យើងខ្ញុំដែលបានផ្តល់កំណើតនិងបានយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ អប់រំថែរក្សាទូន្មានប្រៀនប្រដៅកូនៗតាំងពីតូចដល់ធំ ជាពិសេសលោកតែងតែជួយទំនុកបម្រុងសព្វគ្រប់បែបយ៉ាង ទាំងស្មារតីទាំងសម្ភារៈ និងទាំងប្រាក់កាស ដើម្បីឲ្យកូនបានសិក្សារៀនសូត្រក្រេបយកចំណេះដឹងចាប់តាំងពី កម្រិតបឋមសិក្សា មធ្យមសិក្សា រហូតមកដល់ឧត្តមសិក្សា ដែលគុណតម្លៃនេះបានធ្វើឲ្យកូនៗចងចាំជានិច្ចនូវគុណូបការៈយ៉ាងវិសេសវិសាលក្រៃលែង និងថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងបួន។ គុណូបការៈរបស់លោកទាំងបួនមានទំហំធំធេងមិនអាចមានអ្វីប្រៀបស្មើនិងធ្វើឲ្យកូនៗចងចាំជានិច្ចរហូតតរៀងទៅ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតី តេជោហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន** ដែលជាអគ្គមគ្គុទ្ទេសន៍ដ៏ឆ្នើម របស់ព្រះរាជាណាចក្រកម្ពុជា រួមជាមួយនិងសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ដែលបានចូលរួមដឹកនាំជ្រោមជ្រែង ប្រទេសកម្ពុជាប្រកបដោយគតិបណ្ឌិតដ៏ប្រពៃ ដែលបាននាំមកនូវសុខសន្តិភាពពេញទី ជូនប្រជាជននិងជម្រុញសង្គមកម្ពុជាឲ្យមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សទៅលើគ្រប់វិស័យទាំងអស់។

**ក្រសួងអប់រំ យុវជន និងកីឡា** ដែលបានចូលរួមខិតខំយ៉ាងសកម្មនៅក្នុងការពង្រឹងគុណភាពទៅលើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ចំពោះសិស្សានុសិស្សគ្រប់ជាន់ថ្នាក់ និងបណ្តុះបណ្តាលបាននូវធនធានមនុស្សជាច្រើនសម្រាប់ជាសរសរទ្រូងរបស់ប្រទេសជាតិ ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចម្រើនទៅមុខជាលំដាប់ទៅលើគ្រប់វិស័យ។

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** សូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅចំពោះ**សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង** ដែលបានបង្កើតសាកវិទ្យាល័យនេះឡើង ដើម្បីឲ្យមានភាពងាយស្រួលដល់និស្សិតគ្រប់រូបដែលបន្តការសិក្សាថ្នាក់ឧត្តមសិក្សា និងសូម

ថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ទាំងអស់នៅក្នុងសាកលវិទ្យាល័យ ដែលបានខិតខំផ្ទេរនូវចំណេះដឹងទាំងអស់ជូនទៅដល់និស្សិតគ្រប់រូបសម្រាប់ជាប្រយោជន៍ទៅថ្ងៃអនាគត។

ម្យ៉ាងវិញទៀតយើងខ្ញុំទាំងពីរនាក់សូមសម្តែងការដឹងគុណ ចំពោះលោកសាស្ត្រាចារ្យ **ជ័យ រិទ្ធី** ក្នុងការជួយណែនាំបង្ហាត់បង្ហាញ ពន្យល់នូវមេរៀន ក៏ដូចជាបំពេញបន្ថែមនូវអ្វីដែលជាកង្វះខាតនៅក្នុងការសិក្សារៀនសូត្រ និងពន្យល់ ណែនាំទៅលើការសរសេររបាយការណ៍បញ្ចប់ការសិក្សាមួយនេះទាំងពីដើមរហូតដល់ចប់។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមជូនពរដល់ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យគ្រប់រូប ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចូលរួមសម្របសម្រួលនៅក្នុងដំណើរការសរសេររបាយការណ៍បញ្ចប់ការសិក្សារបស់យើងខ្ញុំ ជាពិសេសលោកសាស្ត្រាចារ្យ **ជ័យ រិទ្ធី** សូមមានសុខភាពល្អជៀសចាកឆ្ងាយជំងឺទាំងពួងទទួលបាននូវជោគជ័យគ្រប់ភារកិច្ចការងារព្រមទាំងពុទ្ធពរទាំងបួនប្រការគឺអាយុវណ្ណៈសុខៈពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំទាំងពីរនាក់ ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៧ ដល់ឆ្នាំ២០២១ បានចំណាយពេលសិក្សារៀនសូត្រនៅទីនេះកន្លងមក ដើម្បីក្រៀបយកនូវចំណេះដឹងដ៏មានតម្លៃនានាយ៉ាងច្រើនសម្បូបែបនៃវិជ្ជាជីវៈដែលសាកលវិទ្យាល័យបានផ្តល់ឲ្យ ក្រោមការបង្ហាត់បង្ហាញយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់រូបនៅទីនេះអស់រយៈពេល៤ឆ្នាំ និងទទួលបាននូវពុទ្ធិជាច្រើនសម្បូរបែបដើម្បីទុកជាស្ពានសម្រាប់អភិវឌ្ឍន៍ខ្លួនឯង និងសង្គមជាតិទាំងមូល។

ជាមួយគ្នានេះផងដែរ ដើម្បីឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ នៅក្នុងការបង្ហាត់បង្ហាញផ្តល់នូវចំណេះដឹងនានានៃវិជ្ជាជីវៈយ៉ាងច្រើនសម្បូរបែបពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់រូប មកដល់រូបយើងខ្ញុំទាំងពីរនាក់នាពេលកន្លងមកនេះ ក៏ដូចជាតម្រូវការចាំបាច់របស់សាកលវិទ្យាល័យនៅពេលបញ្ចប់ការសិក្សា និងដើម្បីចងក្រងជាឯកសារទុកជាស្នាដៃសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយធ្វើការស្រាវជ្រាវបន្ថែមដើម្បីជាប្រយោជន៍រួមនៅក្នុងវិស័យអប់រំ។ លើសពីនេះទៅទៀត យើងខ្ញុំយល់ឃើញថាការសិក្សាទៅលើមុខជំនាញនីតិសាស្ត្រមិនមែនជាជំនាញបិទនោះទេ គឺវាជាមុខជំនាញមួយដែលមានទំនាក់ទំនងយ៉ាងសកម្មជាមួយនិងការអនុវត្តនៃជំនាញផ្សេងៗទៀតនៅក្នុងបរិបទសង្គមសេដ្ឋកិច្ចប្រទេសកម្ពុជាយើង។ ហើយពន្ធដារក៏ជាជំនាញមួយដែលមានការទំនាក់ទំនងគ្នាផងដែរជាមួយនិងនីតិសាស្ត្រនៅក្នុងបរិបទសង្គមសេដ្ឋកិច្ចរបស់កម្ពុជាយើងសព្វថ្ងៃ ម្យ៉ាងវិញទៀតដោយសារតែមើលឃើញពីកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃមានការកើនឡើងជាលំដាប់ទៅលើគ្រប់វិស័យ ជាពិសេសវិស័យអចលនទ្រព្យ និងសំណង់ដែលមួយរយៈពេលចុងក្រោយនេះមានការរីកលូតលាស់ជាលំដាប់ ទើបយើងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទ **ពន្ធលើចំណេញមូលធន** មកធ្វើការសិក្សាលម្អិតដើម្បីឲ្យយល់កាន់តែច្បាស់អំពីគោលការណ៍ច្បាប់ នៅក្នុងប្រតិបត្តិការពន្ធដារនេះដែលជាប្រភេទពន្ធថ្មី ដែលត្រូវបានពន្យាពេលដាក់ឲ្យអនុវត្តនៅក្នុងប្រទេសកម្ពុជាយើង។ ដូច្នេះហើយសង្ឃឹមថា ស្នាដៃរបាយការណ៍បញ្ចប់ការសិក្សាមួយនេះ និងក្លាយទៅជាពុទ្ធិដ៏សំខាន់សម្រាប់អ្នកសិក្សាគ្រប់ជំនាន់។

ជាចុងក្រោយយើងខ្ញុំសូមជូនពរដល់ មិត្តនិស្សិត និងអ្នកអានទាំងអស់គ្នាឲ្យមានសុខភាពល្អជួបតែសេចក្តីសុខគ្រប់ប្រការ រនិងសម្រេចបាននូវជោគជ័យគ្រប់ភារកិច្ចការការងារ។ ជាមួយគ្នានេះផងដែរយើងខ្ញុំទាំងពីរនាក់ក៏សូមសម្តែងនូវភាពរីករាយជានិច្ច និងទទួលយកមតិនៅក្នុងការរិះគន់ក្នុងន័យស្ថាបនាដើម្បីចូលរួមបំពេញចន្លោះខ្វះខាត ឬកំហុសដោយអចេតនាត្រង់ចំណុចណាមួយរបស់យើងខ្ញុំទាំងពីរនាក់នៅលើរបាយការណ៍បញ្ចប់ការសិក្សាមួយនេះ។

# មាតិកា


**សេចក្តីផ្តើម** ..... ០១

**ជំពូកទី១**

**ទិដ្ឋភាពទូទៅនៃប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា**

**ផ្នែកទី១៖ រដ្ឋបាលពន្ធដារ និងទ្រឹស្តីទូទៅនៃពន្ធដារនៅកម្ពុជា** ..... ០៤

**កថាខណ្ឌ១៖ ការវិវត្តនៃច្បាប់ពន្ធដារ** ..... ០៤

**កថាខណ្ឌ២៖ អគ្គនាយកដ្ឋានពន្ធដារ** ..... ០៥

១. ការបង្កើតអគ្គនាយកដ្ឋានពន្ធដារ ..... ០៥

២. រចនាសម្ព័ន្ធអគ្គនាយកកដ្ឋានពន្ធដា ..... ០៦

៣. បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ ..... ០៨

៤. តួនាទីនិងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ..... ០៨

**កថាខណ្ឌ៣៖ ទ្រឹស្តីទូទៅនៃពន្ធដារ** ..... ០៩

១. ពន្ធផ្ទាល់ និងពន្ធប្រយោល ..... ០៩

២. របបពន្ធដារ ប្រភេទពន្ធដារ និងការចុះបញ្ជី ..... ១១

២.១. របបពន្ធដារ ..... ១១

២.២. ប្រភេទពន្ធដារ ..... ១២

២.៣. ការចុះបញ្ជីពន្ធដារ ..... ១២

៣. ការគេចវេសពន្ធ ..... ១៤

**ផ្នែកទី២៖ ការសិក្សា និងការដាក់ឲ្យអនុវត្តពន្ធលើចំណេញមូលធននៅកម្ពុជា** ..... ១៥

**កថាខណ្ឌ១៖ ការសិក្សាក្របខណ្ឌច្បាប់ និងបទពិសោធន៍បរទេសនៃការអនុវត្តពន្ធលើចំណេញមូលធន** ..... ១៥

១. ករណីប្រទេសម៉ាឡេស៊ី ..... ១៥

២. ករណីប្រទេសកូរ៉េខាងត្បូង ..... ១៦

៣. ប្រទេសអូស្ត្រាលី ..... ១៦

៤. ប្រទេសស៊ុយអ៊ែត ..... ១៦

៥. ប្រទេសហ្វីលីពីន ..... ១៧

៦. ប្រទេសថៃ ..... ១៧

**កថាខណ្ឌ២៖ ការដាក់ឲ្យអនុវត្តពន្ធលើចំណេញមូលធននៅកម្ពុជា**..................១៨
១. ក្របខណ្ឌគតិយុត្ត..................១៨
២. អត្ថប្រយោជន៍..................១៩
៣. បញ្ហាប្រឈម និងដំណោះស្រាយ..................១៩

## ជំពូកទី២
## វិធាន និងនីតិវិធីគ្រប់គ្រងពន្ធលើចំណេញមូលធននៅកម្ពុជា

**ផ្នែកទី១៖ កម្មវត្ថុនៃពន្ធ អត្រាពន្ធ និងការគណនាពន្ធ**..................២១
**កថាខណ្ឌ១៖ និយមន័យ និងកម្មវត្ថុនៃពន្ធ**..................២១
១. និយមន័យ..................២១
២. កម្មវត្ថុនៃពន្ធ..................២២
២.១. ដែនវិសាលភាពនៃពន្ធលើចំណេញមូលធន..................២២
២.២.ការលើកលែងពន្ធលើចំណេញមូលធន..................២៣
**កថាខណ្ឌ២៖ អត្រាពន្ធ មូលដ្ឋានគិតពន្ធ និងការគណនាពន្ធ**..................២៣
១. អត្រាពន្ធ មូលដ្ឋានគិតពន្ធ..................២៣
២. ការគណនាពន្ធ..................២៤
២.១. វិធីសាស្ត្រនៃការគណនា..................២៤
២.២. វិធាននៃការកាត់កងចំណាយ..................២៥
២.២.១. មូលធនជាអចលនវត្ថុ..................២៥
២.២.២.មូលធនដទៃទៀត..................២៧
៣. ពន្ធលើចំណេញមូលធនចំពោះទ្រព្យនៅក្រៅព្រះរាជាណាចក្រកម្ពុជា..................២៧
**ផ្នែកទី២៖ ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធ**..................២៨
**កថាខណ្ឌ១៖ ការដាក់លិខិតប្រកាស និងការបង់ពន្ធ**..................២៨
**កថាខណ្ឌ២៖ ឯកសារតម្រូវ**..................២៩
**កថាខណ្ឌ៣៖ ទោសបញ្ញត្តិ**..................២៩
**សេចក្ដីសន្និដ្ឋាន**..................៣១
**អនុសាសន៍**..................៣២
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងប្រទេសជាតិនីមួយៗ អាចទទួលបានការអភិវឌ្ឍន៍ទៅបាន លុះត្រាតែមានការចូលរួមគ្រប់មជ្ឈដ្ឋានពីសំណាក់ប្រជាពលរដ្ឋគ្រប់ៗរូប។ ហើយក្រៅពីការចូលរួមគ្រប់សកម្មភាពនៅក្នុងសង្គម ប្រជាពលរដ្ឋមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ **ពន្ធដារ** គឺជាប្រភពចំណូលយ៉ាងសំខាន់ ក្នុងចំណោមប្រភពចំណូលផ្សេងទៀតនៅគ្រប់ប្រទេសក្នុងពិភពលោក ហើយចំណូលពន្ធដារតែងតែចូលរួមយ៉ាងសកម្មនៅក្នុងសេដ្ឋកិច្ចប្រទេសជាតិ ក៏ដូចជាការអភិវឌ្ឍប្រទេសជាតិឲ្យកាន់តែមានភាពរីកចម្រើនលើគ្រប់វិស័យ និងជាការធានាឲ្យបាននូវភាពរឹងមាំនៃសេដ្ឋកិច្ចប្រទេសជាតិ។ ដូច្នេះហើយ បានជាធ្វើឲ្យគ្រប់បណ្តាប្រទេសទាំងអស់ចាប់ផ្តើមបង្កើតឡើងនូវការប្រមូលពន្ធក៏ដូចជាបានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ឬលិខិតបទបញ្ញាត្តិនានាផ្សេងទៀតដើម្បីគ្រប់គ្រង និងធានាអោយបាននូវប្រសិទ្ធភាពទៅលើការប្រមូលពន្ធ។ ដើម្បីបំពេញតម្រូវការចំណាយប្រចាំឆ្នាំរបស់រដ្ឋ និងការវិវត្តឥតឈប់ឈរនៃសង្គម ពន្ធថ្មីៗត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ទៅតាមភូមិសាស្ត្រ ប្រជាសាស្ត្រ សង្គម និងតម្រូវការចាំបាច់ជាក់ស្តែង។ លើសពីការបង្កើតលិខិតបទដ្ឋានសម្រាប់គ្រប់គ្រងក៏មាននូវវិធានការតឹងទារបំណុលពន្ធ និងទណ្ឌកម្មពន្ធដារនានា នៅក្នុងគោលបំណងធ្វើឲ្យការប្រមូលពន្ធដារកាន់តែមានប្រសិទ្ធិភាព។

ជាក់ស្តែង នៅក្នុងប្រទេសកម្ពុជាការប្រមូលពន្ធក៏ជាកត្តាចាំបាច់ដែលកម្ពុជាយើង បានដាក់ចេញនូវវិធាន និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីទទួលបានចំណូលលើវិស័យពន្ធដារនេះផងដែរ ដើម្បីជំរុញការអភិវឌ្ឍន៍ប្រទេសជាតិអោយមានភាពរីកចម្រើន និងមានសក្តានុពលដែលអាចប្រកួតប្រជែងជាមួយប្រទេសដ៏ទៃផ្សេងទៀតបាន ។ ហេតុននេះហើយបានជាប្រទេសកម្ពុជានៅតែបន្តរក្សាទុកវិស័យពន្ធដារ ដែលបានបន្សល់ទុកនិងចាប់ផ្តើមដោយអាណានិគមនិយមបារាំង និងបានដាក់ចេញនូវពន្ធថ្មីៗជាបន្តបន្ទាប់ទៅតាមស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋ។ ពន្ធទាំងនោះរួមមាន ពន្ធលើអចលនទ្រព្យ ពន្ធលើប្រាក់ចំណេញ ពន្ធអប្បបរមា ពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្ស ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រាពន្ធលើដីធ្លីមិនទាន់ប្រើប្រាស់ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធលើចំណេញមូលធន។ល។ ក្នុងចំណោមបណ្តាពន្ធ ដែលបានដាក់អនុវត្តនៅកម្ពុជា ពន្ធលើចំណេញមូលធនជាពន្ធមួយដែលអគ្គនាយកដ្ឋានពន្ធដារទើបដាក់អោយអនុវត្តថ្មីសម្រាប់ប្រទេសកម្ពុជាយើងដើម្បីប្រមូលចំណូលជូនរដ្ឋ ដោយពន្ធនេះត្រូវប្រមូលពីការលក់ ឬ ផ្ទេរមូលធន ដែលមានដូចជា អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ ភាគហ៊ុន និងកម្មសិទ្ធិបញ្ញា។ តាមពិតទៅពន្ធលើចំណេញមូលធន មានតាំងពីឆ្នាំ២០០៧ មកម្លេះដែលស្ថិតនៅក្នុងបញ្ញត្តិច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ប៉ុន្តែដោយសារពេលនោះកត្តាសេដ្ឋកិច្ចរបស់យើងមិនទាន់មាន

មានភាពល្អប្រសើរ ទើបអគ្គនាយកដ្ឋានពន្ធដារមិនទាន់បានដាក់ពន្ធនេះ សម្រាប់អោយអ្នកមានកាតព្វកិច្ចជាប់ពន្ធអនុវត្ត ហើយបន្តរហូតមកដល់ឆ្នាំ២០២១នេះវិញ។ដោយហេតុបានឃើញថា នៅក្នុងរយៈចុងក្រោយនេះសង្គមសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាយើងមានការកើនឡើងយ៉ាងខ្លាំង ក្នុងវិស័យអចលនទ្រព្យ មានដូចជាវិស័យសំណង់ អគារ ក៏ដូចជាវិស័យភាគហ៊ុនជាដើម។

ពន្ធលើចំណេញមូលធន នៅកម្ពុជាត្រូវបានបង្កើតឡើងដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៨ និងត្រូវបានចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០២១ តទៅនេះ។ ការប្រមូលពន្ធលើចំណេញមូលធន ពិតជាប្រភពចំណូលដ៏សំខាន់មួយទៅថ្ងៃអនាគតក្នុងចំណោមប្រភពចំណូលជាច្រើនផ្សេងទៀត ដោយហេតុថាពន្ធនេះមានកម្មវត្ថុប្រមូលទៅលើវិស័យអចលនទ្រព្យ ភតិសន្យា ភាគហ៊ុន ទ្រព្យវិនិយោគ ភាគហ៊ុន និងរូបិយវត្ថុបរទេស ដែលវិស័យទាំងអស់នេះនៅកម្ពុជាមានសន្ទុះកើនឡើងយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់នៅក្នុងសង្គមសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ននេះ។ ដោយសារតែមើលឃើញពីភាពសំខាន់នៅក្នុងការប្រមូលពន្ធ ទៅលើចំណេញមូលធន ទើបក្រុមយើងខ្ញុំបានជ្រើសរើសប្រធានបទស្តីពី "**ពន្ធលើចំណេញមូលធន**" មកសរសេរជាសារណាបញ្ចប់ការសិក្សា ដើម្បីជាការចូលរួមចែករំលែកនូវចំណេះដឹងផ្នែកពន្ធដារ តាមរយៈការសរសេរពន្យល់ អំពីការប្រមូលពន្ធលើចំណេញមូលធន ដល់អ្នកសិក្សាស្រាវជ្រាវ និស្សិត បញ្ញវន្ត និងប្រជាពលរដ្ឋគ្រប់រូប ជាពិសេសគឺអ្នកជាប់ពន្ធ ឲ្យបានយល់កាន់តែច្បាស់ និងដើម្បីជាការជួយជម្រុញឲ្យពួកគាត់ចូលរួមអនុវត្តកាតព្វកិច្ចបង់ពន្ធឲ្យបានគ្រប់ៗគ្នា។

ការស្រាវជ្រាវនេះមានគោលបំណងចែករំលែកនូវចំណេះដឹងទាក់ទងទៅនិង វិស័យពន្ធដារនិងពន្យល់ អំពីពន្ធអត្ថន័យនៃការយកពន្ធលើចំណេញមូលធន។ ជនទាំងឡាយមិនថាជានិវាសនជន ឬ អនិវាសនជន ដែលបានចំណេញពីការផ្ទេរ ឬ លក់ មូលធនត្រូវមានកាតព្វកិច្ចបង់ពន្ធទៅតាមច្បាប់ដែលបានកំណត់។ ការសិក្សាអំពីពន្ធលើចំណេញមូលធន បានដកស្រង់យក ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងឯកសារនានាដើម្បីចងក្រងឡើង ក្នុងគោលបំណងស្វែងយល់អំពីពន្ធមួយប្រភេទនេះ និងស្រាវជ្រាវអោយកាន់តែស៊ីជម្រៅអំពីការអនុវត្ត និងនីតិវិធីនៃការប្រមូលពន្ធលើចំណេញមូលធននៅព្រះរាជាណាចក្រកម្ពុជា។

លទ្ធផលដែលកើតចេញពីការស្រាវជ្រាវនេះនឹងចូលរួមចំណែកផ្តល់ជាចំណេះដឹង ទាក់ទងទៅនឹងការប្រមូលពន្ធលើចំណេញមូលធន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលអនុលោមទៅតាមច្បាប់ស្តីពីសារពើពន្ធកម្ពុជា។ ជាងនេះទៅទៀត ក៏នឹងជួយជម្រុញជនដែលជាប់កាតព្វកិច្ចបង់ពន្ធ ឲ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ពន្ធជូនរដ្ឋ ដែលអាចឲ្យរដ្ឋមានចំណូលសម្រាប់គ្រប់គ្រង និងអភិវឌ្ឍប្រទេសជាតិឲ្យកាន់តែមានភាពរីកចម្រើនជានិរន្តរ៍។

វិសាលភាពនៃការស្រាវជ្រាវនេះផ្តោតសម្ខាន់ទៅលើ ពន្ធលើចំណេញមូលធន រួមជាមួយនិងការរំលឹកអំពីទ្រឹស្តីពន្ធដារក៏ដូចជាវិធាននានាដែលត្រូវបានដាក់ឲ្យអនុវត្ត ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានពន្ធដារជាសេនាធិការ សម្រាប់អនុវត្តទៅលើការប្រមូលពន្ធ សម្រាប់ប្រមូលពន្ធ និងបង្កើនចំណូលថវិការជូនរដ្ឋ។

តើពន្ធលើចំណេញមូលធនត្រូវបានអនុវត្តទៅលើអ្វីខ្លះ? ហើយត្រូវបានគណនាយ៉ាងដូចម្តេច? ផ្អែកទៅលើអ្វីជាមូលដ្ឋានគិតពន្ធ? ហើយរដ្ឋធ្វើការប្រមូលពន្ធតាមរបៀបណា? ដើម្បីធ្វើការបកស្រាយប្រធានបទ **ពន្ធលើចំណេញមូលធន** ឲ្យបានស៊ីជម្រៅ លម្អិត និងគ្រប់ជ្រុងជ្រោយឆ្លើយតបទៅនិងបញ្ហាគតិយុត្ត ដែលបានចោទខាងលើនេះ ការស្រាវជ្រាវនេះត្រូវបានរៀបចំជាពីរជំពូកធំៗដូចខាងក្រោម៖

**ជំពូកទី១៖ ទិដ្ឋភាពទូទៅនៃប្រព័ន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា**

**ជំពូកទី២៖ វិធាន និងនីតិគ្រប់គ្រងពន្ធលើចំណេញមូលធននៅកម្ពុជា**

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃ
# ប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រ
# កម្ពុជា

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃប្រព័ន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា
## ផ្នែកទី១៖ រដ្ឋបាលពន្ធដារ និងទ្រឹស្តីទូទៅនៃពន្ធដារនៅកម្ពុជា
### កថាខណ្ឌ១៖ ការវិវត្តនៃច្បាប់ពន្ធដារ

រដ្ឋខ្មែរបានចាប់កំណើតនៅក្នុងសតវត្សទី១នៃគ្រិះសករាជ ពោលគឺនៅក្នុងសម័យហ្វូណន។ ហើយការប្រមូលពន្ធមានតាំងតែពីសម័យបុរាណកាលមកម្លេះ តាមប្រវត្តិសាស្ត្របន្តពីសម័យហ្វូណន មានសម័យកាលជាច្រើនទៀតដូចជាសម័យចេនឡាអង្គរ លង្វែក ឧត្តុង្គនិងចតុមុខ។ ការកំណត់សម័យកាលទាំងនេះធ្វើឡើង ដោយផ្អែកលើការផ្លាស់ប្តូររាជធានីពីមួយកន្លែងទៅមួយកន្លែងដែលមានរយៈពេលប្រមាណ១៥០០ឆ្នាំ។នៅក្នុងសម័យកាល ទាំងនោះ ត្រូវបានគេសង្កេតឃើញថាព្រះរាជាបានប្រមូលពន្ធពីប្រជារាស្ត្រ ដោយសារព្រះអង្គបានប្រទានដីធ្លីដល់ប្រជារាស្ត្រ ដើម្បីប្រកបអាជីវកម្ម ឬ កសិកម្មជាដើម។

**ពន្ធ** គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតព្វកិច្ចរបស់គ្រប់សមាសភាពដែលកំណត់ដោយច្បាប់និងមានទិសដៅបំពេញរាល់ការប្រើប្រាស់របស់រដ្ឋ។ ក៏ប៉ុន្តែការប្រមូលពន្ធនាសម័យនោះមានការកំណត់អាត្រាពន្ធមិនបានច្បាស់លាស់សមធម៌ និងជាក់លាក់តាមច្បាប់កំណត់នោះទេគឺច្បាប់ទាំងអស់ស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់ព្រះមហាក្សត្រឬបុគ្គលដែលមានអំណាចខ្លាំងក្លាតែប៉ុណ្ណោះ។ លុះមកដល់ក្នុងឆ្នាំ១៨៦៣ បារាំងបានចូលមកធ្វើជាអាណាព្យាបាលខ្មែរ ហើយក្រោយមកបានប្រែក្លាយកម្ពុជាទៅជាទឹកដីអាណានិគមរបស់ខ្លួននាឆ្នាំ១៨៨៤ ហើយពេលនោះបារាំងបាននាំយកច្បាប់ និងការគ្រប់គ្រងរដ្ឋបាលមកអនុវត្តនៅកម្ពុជា ជាពិសេសវិស័យសារពើពន្ធ។ ក្រោយមកនៅពេលដែលប្រទេសកម្ពុជា ទទួលបានឯករាជ្យពីអាណានិគមនិយមបារាំងនាថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាមានភាពពិបាកនៅក្នុងការវិលត្រឡប់ទៅរកការអនុវត្តច្បាប់ខ្មែរបុរាណវិញណាស់ ដោយហេតុថាប្រទេសកម្ពុជាពេលនោះបានក្លាយខ្លួនទៅជាគ្រួសាររបស់ប្រព័ន្ធច្បាប់រ៉ូម៉ាំង (អាឡឺម៉ង់) រួចទៅហើយ។ ជាវិបាកប្រព័ន្ធពន្ធដារនៅក្នុងប្រទេសកម្ពុជាគឺមានឬសគល់ចេញពីច្បាប់របស់ប្រទេសបារាំង។[1]

បន្ទាប់មកនៅក្នុងឆ្នាំ១៩៩៧ ច្បាប់ស្តីពីសារពើពន្ធ និងបទបញ្ញត្តិច្បាប់ផ្សេងៗទៀតក៏ត្រូវបានបង្កើតឡើងដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយការបង្កើតច្បាប់នេះគឺឆ្លើយតបទៅនិងមាត្រា ៥៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានចែងថាការយកពន្ធដារនិងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត្តិ។ ច្បាប់ស្តីពីសារពើពន្ធ របស់កម្ពុជាត្រូវបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ២០០៣។ មកដល់ពេលបច្ចុប្បន្ននេះប្រព័ន្ធច្បាប់ពន្ធ

[1] នីតិពន្ធដារ របស់លោកគ្រូ គង់ ប៊ុនធី ជំពូកទី១ សេចក្តីផ្តើមសារពើពន្ធ។

ដារ នៅក្នុងប្រទេសកម្ពុជា កំពុងតែមានការអភិវឌ្ឍន៏ជាបន្តបន្ទាប់ដើម្បីឲ្យស្របទៅតាមប្រទេស ដែលមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដោយពង្រឹងនូវមូលដ្ឋានគិតពន្ធ និងពង្រឹងនូវការគោរពច្បាប់សារពើពន្ធផងដែរ។

**កថាខណ្ឌ២៖ អគ្គនាយកដ្ឋានពន្ធដារ**

**១. ការបង្កើតអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៣ ដែលនៅក្នុងសម័យនោះមានឈ្មោះថាជា**នាយកដ្ឋានពន្ធដារ** បន្ទាប់ពីពេលនោះមកប្រទេសកម្ពុជាក៏បានជួបនូវវិបត្តិ សង្គ្រាមដ៏រ៉ាំរ៉ៃយ៉ាងខ្លាំងក្លាអស់រយៈកាលជាយូនៅក្នុងប្រទេស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅក្នុងរបបនេះកម្ពុជាពុំទទួលស្គាល់នូវកម្មសិទ្ធិឯកជននោះទេគឺថាអ្វីៗទាំងអស់ជារបស់សហករ និងសមូលហភាព និងគ្មានចរាចរណ៍រូបិយវត្ថុ គ្មានពាណិជ្ជកម្មនោះទេហេតុនេះហើយក៏មិនមានប្រមូលពន្ធអាករសារពើពន្ធអីដែរ ដូច្នេះហើយទើបប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់នៅក្នុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ បន្ទាប់មកនៅពេលដែលកម្ពុជាទទួលបាននូវជ័យជំនះទៅលើរបបកម្ពុជាប្រជាធិបតេយ្យរួចមក កម្ពុជាក៏បានបង្កើតឡើងនូវ **នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នៅក្នុងឆ្នាំ១៩៨០ ដល់ ឆ្នាំ១៩៩៣ ហើយការបង្កើតឡើងនៅនាយកដ្ឋានពន្ធដារនេះ គឺដើម្បីគ្រប់គ្រងការប្រមូលចំណូលនាសម័យលកាលនោះអោយមានភាពល្អប្រសើរ ហើយបន្ទាប់មកនៅក្នុងឆ្នាំ១៩៨៥ ក៏មានការដាក់ចេញជាក្រឹត្យច្បាប់ស្តីពីពន្ធប៉ាតង់[2] និងបទបញ្ញត្តិច្បាប់ផ្សេងៗទៀតដើម្បីប្រមូលចំណូលពន្ធ និងអាករ ផ្សេងៗទៀតនៅក្នុងសម័យកាលនោះផងដរ។ រហូតមកដល់ក្នុងឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០០៨ ខ្មែរយើងក៏បានប្តូរឈ្មោះពីរដ្ឋកម្ពុជាទៅជាព្រះរាជាណាចក្រកម្ពុជា ហើយនៅក្នុងពេលនោះនាយកដ្ឋានពន្ធដារ ក៏បានក្លាយទៅជា**អង្គភាពពន្ធដារ** ដែលអង្គភាពពន្ធដារនេះស្ថិតនៅក្រោម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសារមើលឃើញពីតម្រូវការនៃការបំពេញមុខងារនិងភារកិច្ចរបស់នាយកដ្ឋានពន្ធដារ ឆ្លើយតបជាមួយនិងកំណើនសង្គមសេដ្ឋកិច្ចរបស់របស់ប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០០៨ ទៅកម្ពុជាក៏បានតម្លើងនាយកដ្ឋានពន្ធដារ ទៅជា **អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ** ។[3]

[2] ក្រឹត្យច្បាប់ស្តីពីពន្ធប៉ាតង់ ឆ្នាំ១៩៨៥

[3] អនុក្រឹត្យស្តីពី ការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,លេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ កញ្ញា ២០០៨

ក្រោយមកនៅឆ្នាំ២០១៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំកែសម្រួលនូវរចនាសម្ព័ន្ធ និងដំណើរការនៃប្រព្រឹត្តិទៅជាថ្មី ដែលមានចែងនៅក្នុងអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ត្រង់មាត្រា ៣៥ ដល់មាត្រា ៣៩។[4]

**២.រចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ មានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាល និងមូលដ្ឋានដូចខាងក្រោម ៖

**ថ្នាក់កណ្តាលរួមមាន ៖**

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារលើការងាររដ្ឋបាល និងកិច្ចការទូទៅ។
- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារទៅលើការងារហិរញ្ញវត្ថុ និងបុគ្គលិក។
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារនីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការអន្តរជាតិ។
- នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារលើការគ្រប់គ្រងពន្ធចលទ្រព្យ និងអចលនទ្រព្យ។
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារបច្ចេកវិទ្យាព័ត៌មាន។
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារស៊ើបអង្កេតបទល្មើសពន្ធដារ។
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារ លើការគ្រប់គ្រងអ្នកជាប់ពន្ធធំ។
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារលើការងារគ្រប់គ្រងសាខាពន្ធដារខេត្ត-ខណ្ឌ។
- នាយកដ្ឋានសវនកម្មសហគ្រាស បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារសវនកម្មសហគ្រាស។

[4] អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ស្តីពីការរៀបចំប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៦ តុលា ឆ្នាំ២០១៣

- សាលាជាតិពន្ធដារ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារបណ្ដុះបណ្ដាលមុខជំនាញទាក់ទងនឹងពន្ធដារ។
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារសម្របសម្រួលខាងសាខាពន្ធដារខណ្ឌទាំងអស់នៅរាជធានីភ្នំពេញ។

**ថ្នាក់មូលដ្ឋានរួមមាន៖**

- សាខាពន្ធដារខណ្ឌនៅក្នុងរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តនីមួយៗ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពន្ធដារ លើការគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងអ្នកជាប់ពន្ធដ៏ទៃទៀតតាមការចាំបាច់។
- ការិយាល័យពន្ធដារស្រុក ក្រុង នៅតាមខេត្តនីមួយៗ។[5]




[5] អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ស្តីពីការរៀបចំប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៦ តុលា ឆ្នាំ២០១៣,លេខ ៧៥ អនក្រ.បក ២៥ ឧសភា ឆ្នាំ២០១៧ មាត្រា ៦ ,និងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ,លេខ ១២៣២ សហវ.ក្រ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០១៧ ប្រការ ៧ និង ៨

**៣.បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឲ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមានការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឲ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឲ្យច្បាប់នានាស្តីពីនូដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំប្រកដោយប្រសិទ្ធិភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឲ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឲ្យមានប្រសិទ្ធិភាព
- បង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

**៤.តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារមានតួនាទី និងភារកិច្ចដូចខាងក្រោះ

- រៀបចំគោលនយោបាយសារពើពន្ធនិងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រៀងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា លិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការសង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ

- កសាងកម្មវិធី និងអនុវត្តការងារសេវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិការជាតិជាប្រចាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

**កថាខណ្ឌ៣៖ ទ្រឹស្តីទូទៅនៃពន្ធដារ**

ពន្ធមានលក្ខណៈចាប់បង្ខំ ហើយមិនសងអោយវិញផ្ទាល់ ប៉ុន្តែនិងអាចសងឲ្យវិញជាលក្ខណៈរូបភាពប្រយោល ទៅតាមគោលនយោបាយរដ្ឋាភិបាលប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្ម ដែលចំណុះឲ្យគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវមានកាតព្វកិច្ចនិងទំនួលខុសត្រូវចំពោះច្បាប់រដ្ឋ ក្នុងការអនុវត្តឲ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយដែលបានកំណត់ និងមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលមកវិញនៅផលប្រយោជន៍ពីរដ្ឋាភិបាល ដែលប្រកបដោយយុត្តិធម៌ និងត្រូវបានរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលមកវិញតាមរយៈគោលនយោបាយដែលមានចែងក្នុងច្បាប់។[6] ពន្ធគឺជារូបភាពនៃការបែងចែកឡើងវិញនូវចំណូលជាតិដែលរាជរដ្ឋាភិបាល ប្រើប្រាស់ដើម្បីប្រមូលចំណូល មួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ច ដូចជាក្រុមហ៊ុន សហគ្រាស អាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម និងប្រជាពលរដ្ឋ ដើម្បីបម្រើឲ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល ។

ពន្ធដារ គឺជារូបធាតុនៃការប្រមូលចំណូលមួយដែលផ្សារភ្ជាប់ជាមួយនិង សិទ្ធិអំណាច នយោបាយរបស់រដ្ឋាភិបាល ដែលក្រឹត្យច្បាប់កំណត់។

ពន្ធដារ គឺជាការបង់វិភាគទាននូវកាតព្វកិច្ចរបស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់។

**១.ពន្ធផ្ទាល់ និងពន្ធប្រយោល**

**+ ពន្ធផ្ទាល់**

ពន្ធផ្ទាល់ គឺជាពន្ធទាំងឡាយណាដែលរដ្ឋបានកំណត់ប្រមូលយកចំពោះកម្មវត្ថុផ្ទាល់ នៃពន្ធលើបុគ្គល ឬ ទ្រព្យសម្បត្តិរបស់បុគ្គល។ បុគ្គលជាប់ពន្ធមានទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ដែលមានស្ថានភាពគតិយុត្តជាពាណិជ្ជករ អាជីវករ អាជីវកម្ម ឬកម្មសិទ្ធិករជាដើម។ចំណែកឯទ្រព្យសម្បត្តិសម្បត្តិជាប់ពន្ធមានទាំងចលន

[6] នីតិពន្ធដារ ទំព័រ១ សញ្ញាណទូទៅនៃពន្ធដារ សាស្ត្រាចារ្យ វ៉ីន ឈុនហួត សាកលវិទ្យាល័យឯកទេសនៃកម្ពុជា

ទ្រព្យ និងអចលនទ្រព្យ ដែលមានដូចជារថយន្ត ដី ផ្ទះ អាគារ និងសំណង់ផ្សេងៗជាដើម។ ខាងក្រោមនេះ គឺជាឧទាហរណ៍ពីពន្ធមួយចំនួនដែលប្រភេទនៃពន្ធផ្ទាល់នៅកម្ពុជា រួមមាន ៖

- ពន្ធលើឈ្នួលផ្ទះ និងដី គឺជាពន្ធដែលត្រូវកំណត់យកលើប្រាក់ឈ្នួល ដែលទទួលបានមកពីការជួលដីធ្លី ឬផ្ទះ អគារ ឬសំណង់ផ្សេងៗ។[7]
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺជាពន្ធដែលត្រូវកំណត់យកលើដីគ្មានសំណង់ទុកទំនេរចោលមិនបានប្រើប្រាស់ និងដីមានសំណង់បោះបង់ចោលស្ថិតនៅក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយ ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។[8]
- ពន្ធប្រថាប់ត្រា គឺជាពន្ធដែលត្រូវកំណត់យកតាមអត្រា ៤% ចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើអចលនទ្រព្យ តាមរយៈការលក់ ការដូរ ការទទួលអំណោយ និងការដាក់ភាគទុនក្រុមហ៊ុន។[9]
- ពន្ធប៉ាតង់ គឺជាពន្ធដែលត្រូវកំណត់យកលើផលរបរសរុបប្រចាំឆ្នាំ ដែលត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។[10]
- ពន្ធលើប្រាក់ចំណូល គឺជាពន្ធដែលត្រូវកំណត់យកលើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលប្រភពក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។[11]
- ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែដែលត្រូវកំណត់យកលើប្រាក់បៀវត្ស ដែលរូបវន្តបុគ្គលបានទទួលនៅក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ។[12]
- ពន្ធលើអចលនទ្រព្យ គឺជាពន្ធដែលត្រូវកំណត់យកលើអចលនទ្រព្យ មានដូចជា ដី ផ្ទះ អគារ និងសំណង់ផ្សេងៗជាដើម។[13]

[7] ប្រកាសស្តីពីការស្តីពីការគ្រប់គ្រងប្រមូលពន្ធលើប្រាក់ឈ្នួលផ្ទះនិងដី, លេខ ០២១ សហវ.ប្រក,ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ១៩៩៤

[8] ប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់,លេខ ២២៤ សហវ.ពដ.ប្រក,ចុះថ្ងៃទី០៥ កក្កដា ឆ្នាំ១៩៩៦

[9] ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា,លេខ ៥០៧ សហវ.ប្រក,ចុះថ្ងៃទី២៦ មេសា ឆ្នាំ២០១៧

[10] ប្រកាសស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់,លេខ១៨២១ សហវ.ប្រក,ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥

[11] ប្រកាសស្តីពីពន្ធលើប្រាក់ចំណូល,លេខ ០៩៨ សហវ.ប្រក,ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២០

[12] ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស,លេខ ១១៧៣ សហវ.ពដ.ប្រក,ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣

[13] ប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ,លេខ ៤៩៣ សហវ.ប្រក,ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០

**+ ពន្ធប្រយោល**

ពន្ធប្រយោល គឺជាប្រភេទពន្ធទាំងឡាយណាដែលរដ្ឋបានកំណត់ប្រមូលយកដោយប្រយោលចំពោះបុគ្គលតាមរយៈការប្រមូលពន្ធលើថ្លៃទំនិញ ឬ សេវាកម្មនានា ដែលបុគ្គលម្នាក់ៗបានប្រើប្រាស់។ ខាងក្រោមនេះគឺជាឧទាហរណ៍ពីពន្ធមួយចំនួនដែលជាប្រភេទនៃពន្ធប្រយោលនៅកម្ពុជា មានដូចជា៖

- អាករសម្រាប់បំភ្លឺសាធារណៈ គឺជាពន្ធដែលកំណត់យកតាមអត្រា ៣% ។[14]
- អាករលើតម្លៃបន្ថែមគឺជាពន្ធដែលត្រូវកំណត់យកលើការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មឲ្យអតិថិជន។ **ទំនិញ** សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លី និងប្រាក់កាស រីឯ **សេវា** សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។[15]
- អាករលើការស្នាក់នៅ គឺជាពន្ធដែលត្រូវបានកំណត់យកតាមអត្រា ២% លើការស្នាក់នៅក្នុងសណ្ឋាគារ និង ផ្ទះសំណាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[16]
- អាករពិសេសលើទំនិញនិងសេវាមួយចំនួន គឺជាពន្ធដែលត្រូវបានកំណត់យកលើទំនិញ និងសេវាមួយចំនួន ដូចជាភេសជ្ជៈ ស្រាបៀរ បារី សេវាលំហែកម្សាន្ត សេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស និងសេវាទូរស័ព្ទ។[17]

## ២. របបពន្ធដារ ប្រភេទពន្ធដារ និងការចុះបញ្ជី

### ២.១. របបពន្ធដារ

របបពន្ធដារនៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ២០១៦មានពីរប្រភេទគឺ របប**ពន្ធតាមរបបពិត "ស្វ័យប្រកាស"** និងរបប **ពន្ធតាមរបបម៉ៅការ** ប៉ុន្តែរហូតមកដល់ឆ្នាំ២០១៦ដោយយោងទៅតាមមាត្រា១០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០១៦ បានលុបចោលការបង់ពន្ធតាមរបបម៉ៅការ និងបង្កើតរបបកំណត់ពន្ធតែមួយគឺ **របបស្វ័យប្រកាស** ។ គោលនយោបាយលុបចោលរបបពន្ធម៉ៅការនេះគឺជាយន្តការលើកទឹកចិត្តចំពោះអាជីវកម្មតូចតាច ដែលមានផលរបរតិចជាង ២៥០លានរៀលក្នុងមួយឆ្នាំនិងមានគោលបំណង សម្រាលបន្ទុកចំណាយ

[14] ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ,លេខ ១៧៥ សហវ.ពដ.ប្រក,ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០២។

[15] អនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម,លេខ ១១៤ អនក្រ.បក, ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៥។

[16] ប្រកាសស្តីពីការអនុវត្តន៍អាករលើការស្នាក់នៅ,លេខ ៣៨០ សហវ.ពដ.ប្រក,ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៥។

[17] អនុក្រឹត្យស្តីពីការកែសម្រួលអត្រាអករពិសេសលើមុខទំនិញមួយចំនួន,លេខ ១៥០ អនក្រ.បក,ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០១៤ និងប្រកាសស្តីពីការណែនាំអនុវត្តការប្រមូលអាករពិសេសលើទំនិញនិងសេវាមួយចំនួន,លេខ ១១៣៣ សហវ.ពដ.ប្រក,ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣។

របស់អាជីវករតូចតាចដែលប្រកបអាជីវកម្មសម្រាប់ត្រឹមតែផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។[18] ហើយ**របបពន្ធតាមរបបពិត "ស្វ័យប្រកាស"** គឺជាប្រព័ន្ធគ្រប់គ្រងពន្ធមួយប្រភេទដែលរាជរដ្ឋាភិបាលកម្ពុជាប្រើចំពោះសហគ្រាសខ្នាតធំ និងមធ្យមគ្រប់ប្រភេទមានដូចជា សហគ្រាសនាំចេញ-ចូល សហគ្រាសវិនិយោគដែលមានលក្ខណៈគតិយុត្ត ហើយសហគ្រាសទាំងនោះធ្វើការប្រកាសពន្ធដោយខ្លួនឯង។

### ២.២.ប្រភេទពន្ធដារ

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃមានពន្ធជាច្រើនប្រភេទដូចជា ពន្ធលើប្រាក់បៀវត្ស ពន្ធលើប្រាក់ចំណេញ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណូល ពន្ធអប្បរមា ពន្ធលើឈ្នួលផ្ទះ និងដី ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ ពន្ធតែមប្រៃសណីយ៍ ។ល។ ចំណែកឯអាករវិញមានដូចជា អាករសម្រាប់បំភ្លឺសាធារណៈ អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករលើការស្នាក់នៅ ជាដើម ។ ហើយពន្ធទាំងអស់នេះមានលក្ខណៈផ្សេងៗគ្នាដែលបានកំណត់ដោយរាជរដ្ឋាភិបាល ហើយពន្ធនីមួយៗសុទ្ធសឹងតែមានលក្ខណៈពិសេសសម្រាប់ជួយដល់រាជរដ្ឋាភិបាលនៅក្នុងការចំណាយនានា សម្រាប់គ្រប់គ្រងមន្ត្រីរាជការនៅក្នុងការបម្រើប្រទេសជាតិមាតុភូមិនីមួយៗដើម្បីឈានទៅរកការអភិវឌ្ឍន៍នៅក្នុងទៅលើគ្រប់វិស័យ។

### ២.៣. ការចុះបញ្ជីពន្ធដារ

យោងទៅតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ **៧០១ ស.ហ.វ** ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០[19] និងស្របទៅតាមមាត្រា១០១ នៃច្បាប់ស្តីពីសារពើពន្ធ បានកំណត់នូវវិធាន និងនីតិវិធីនៃការចុះបញ្ជីពន្ធដារ ក្នុងគោលដៅពង្រឹង និងបង្កើនវិសាលភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រងឲ្យបានកាន់តែប្រសើរនូវទិន្នន័យរបស់អ្នកជាប់ពន្ធ និងគាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានកាន់តែប្រសើរឡើង ព្រមទាំងគាំទ្រដល់ការគ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធឲ្យកាន់តែមានតម្លាភាព និងប្រសិទ្ធិភាព។ ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធទាំងឡាយ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងប្រកាសលេខ **៤៩៦ ស.ហ.វ** នេះបានកំណត់អំពីនិយមន័យ និងឯកសារតម្រូវផ្សេងៗដើម្បី ធ្វើការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារមានដូចខាងក្រោម៖

**ប្រការ ៣.- និយមន័យ** សម្រាប់គោលដៅប្រកាសនេះ៖

[18] បទបង្ហាញស្តីពីទិដ្ឋភាពទូទៅ នៃច្បាប់ពន្ធដារ និងការអនុវត្តក្នុងឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានពន្ធដារ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦។

[19]ប្រកាសស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០។

ក- ពាក្យ "ការចុះបញ្ជីពន្ធដារ" សំដៅដល់អ្នកជាប់ពន្ធទាំងឡាយ ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងប្រកបអាជីវកម្មធម្មតាតាមប្រព័ន្ធអេឡិចត្រូនិច។

ខ-ពាក្យ"អ្នកជាប់ពន្ធ"សំដៅដល់បុគ្គលទាំងឡាយដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។

គ- ពាក្យ "អាជីវកម្ម" សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលក្នុងគោលដៅផលិត និងលក់ទំនិញ ផ្គត់ផ្គង់សេវា ភតិសន្យា ជួលឬលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀតរួមទាំងសកម្មភាពរបស់ ស្ថាប័ន ឬអង្គការនានាដូចមានចែងនៅក្នុងកថាខណ្ឌ៣ មាត្រា៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

ឃ- ពាក្យ "សកម្មភាពសេដ្ឋកិច្ច" សំដៅដល់សកម្មភាព របស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរកឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាឲ្យដល់បុគ្គលដ៏ទៃ ក្នុងគោលដៅដើម្បីអត្ថប្រយោជន៍អ្វីមួយ។

ង- ពាក្យ "បុគ្គល" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

ច- ពាក្យ "ទីចាត់ការសហគ្រាស" សំដៅដល់ទីកន្លែងគ្រប់គ្រងប្រតិបត្តិការអាជីកម្មរបស់សហគ្រាស។

ឆ- ពាក្យ "ទីកន្លែងប្រកបអាជីវកម្មជាគោលដើម" សំដៅដល់ទីកន្លែងជាគោលដើមសម្រាប់ផ្គត់ផ្គង់ទំនិញ ឬសេវាសហគ្រាស។

ជ- ពាក្យ "សាខា" សំដៅដល់កន្លែងផ្គត់ផ្គង់ទំនិញ ឬសេវា ដែលមិនមែនជាទីកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់សហគ្រាស។

**ប្រការ ៤.- ការចុះបញ្ជីពន្ធដារ**

១- បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពេលទទួលបានលិខិតបញ្ជាក់ពីការចុះបញ្ជី ឬលិខិតអនុញ្ញាតិចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ បុគ្គលដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារ ជាអាទិ៍មាន៖

ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តការបច្ចេកទេស រដ្ឋភិបាលនានា និងគណបក្សនយោបាយ។

ខ. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សាខាក្រុមហ៊ុនបរទេស ការិយាល័យតំណាង សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិត សហគ្រាសសាធារណៈ សហគ្រាសរដ្ឋ និងក្រុមហ៊ុនចម្រុះរដ្ឋ។

គ. សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ឃ.បុគ្គលដទៃទៀតដែលធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- បុគ្គលដែលមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រកាសនេះ ត្រូវបានតម្រូវឲ្យចុះបញ្ជីពន្ធដារស្រប តាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬកម្រិតផលរបរ ដូចមានចែងនៅក្នុងច្បាប់និងបទបញ្ញត្តិ ស្តីពីពន្ធដារ និងត្រូវស្នើសុំចុះបញ្ជីទៅតាមទម្រង់ទ្រាយគតិយុត្តនៃបុគ្គលស្នើសុំដូចខាងក្រោម៖

ក.បុគ្គលដែលមានចែងក្នុងវាក្យខណ្ឌ**ខ**នៃកថាខណ្ឌ១នៃប្រកាសនេះការចុះបញ្ជី ពន្ធដារត្រូវធ្វើ ឡើងតាមរយៈ គេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservice.gov.kh ស្របទៅតាមការ កំណត់ដូចមានចែងក្នុងអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវ កម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ បុគ្គលដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃគេហទំព័រចុះបញ្ជីអាជីវកម្ម នឹងទទួលបានឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារជាទម្រង់ឌីជីថលដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជី អាជីវកម្មនេះ។

ខ. បុគ្គលដែលមានចែងក្នុងវាក្យខណ្ឌ **ក** វាក្យខណ្ឌ **គ** និងវាក្យខណ្ឌ **ឃ** នៃកថាខណ្ឌ១ នៃ ប្រកាសនេះ ឬបុគ្គលណាមួយដែលមានបំណងចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬមិនអាចធ្វើការចុះ បញ្ជីតាមគេហទំព័រចុះបញ្ជីអាជីវកម្មបាន ការចុះបញ្ជីពន្ធដារត្រូវធ្វើឡើងតាមរយៈការបំពេញព័ត៌មាននិងភ្ជាប់ឯក សារតម្រូវ ដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់១០១ ) ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

៣-រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងប្រាក់ពន្ធ-កម្រៃ សេវាដោយបញ្ជាក់កាលបរិច្ឆេទនៃការប្រគល់ទទួល បន្ទាប់ពីបានពិនិត្យឃើញថាសុំណុំឯកសារស្នើសុំនោះ ត្រឹមត្រូវ និងគ្រប់គ្រាន់។ ដោយឡែក ការស្នើសុំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធរបស់បុគ្គលដូចមានចែងក្នុង វាក្យខណ្ឌ ខ នៃកថាខណ្ឌ១ នៃប្រការនេះ រដ្ឋបាលសារពើពន្ធ ត្រូវបំប្លែងឯកសារ បញ្ចូលព័ត៌មានការ ស្នើសុំចុះបញ្ជី និងសម្របសម្រួលទូទាត់ប្រព័ន្ធ-កម្រៃសេវាចុះបញ្ជីទៅតាម គេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservice.gov.kh ឲ្យបានរួចរាល់ និងត្រូវចេញលិខិតការបញ្ជាក់ការទទួលពាក្យស្នើ សុំចុះបញ្ជី និងប្រាក់ពន្ធ-កម្រៃសេវាចុះបញ្ជី នៅក្រោយពេលបានទទួលលិខិតជាសារអេឡិចត្រូនិចបញ្ជាក់ការ ទទួលពាក្យស្នើសុំពីគេហទំព័រចុះបញ្ជីអាជីវកម្ម។

**៣.ការគេចវេសពន្ធ**

អ្នកជាប់ពន្ធតែងរកវិធីផ្សេងៗដើម្បីកាត់បន្ថយការបង់ពន្ធ ទោះបីជាត្រូវបានធ្វើឲ្យមើលទៅស្របច្បាប់ក៏ ដោយ ក៏វានៅតែផ្ទុយពីស្មារតីច្បាប់ដដែល។ ហើយសកម្មភាពនេះត្រូវបានគេហៅថា អប្បដិបត្តិ។

ការគេចវេសពន្ធ គឺជាអំពើខុសច្បាប់ដោយចេតនា ព្រោះមានការគិតទុកជាមុន និងច្រើនដងទៅលើអ្វីដែលមានចែងនៅក្នុងច្បាប់ស្ដីពីសារពើពន្ធ ធ្វើយ៉ាងណាកាត់បន្ថយប្រាក់បង់ពន្ធឲ្យមានចំនួនកាន់តែតិចទៅៗ។ ជាងនេះទៅទៀត ការធ្វេសប្រហែសដែលមានលក្ខណៈធ្ងន់ធ្ងរ ក៏ត្រូវចាត់ទុកថាជាការគេចពន្ធផងដែរ។

ការគេចវេសពន្ធ ត្រូវបានចាត់ទុកថាជាបទល្មើសចេតនាបានរៀបចំទុកជាមុន។ ប្រសិនបើកើតឡើងដោយការធ្វេសប្រហែសធ្ងន់ធ្ងរពីរលើកដាច់ពីគ្នា ក្នុងរយៈពេលបីឆ្នាំប្រតិទិន ឬបីលើក ឬច្រើនពីហ្នឹងដាច់ពីគ្នាក្នុងរយៈពេលណាមួយក៏ដោយ គឺត្រូវចាត់ទុកថាជាបទល្មើសដោយចេតនាដែរ ហើយអាចត្រូវផ្ដន្ទាទោសពី ដប់លាន ១០.០០០.០០០ ទៅម្ភៃលាន ២០.០០០.០០០ រៀល ឬអាចជាប់ពន្ធនាគារពី ១ឆ្នាំ ទៅដល់ ៥ឆ្នាំ ឬទោសទាំងពីរតែម្ដង។[20]

## ផ្នែកទី២៖ ការសិក្សា និងការដាក់ឲ្យអនុវត្តពន្ធលើចំណេញមូលធននៅកម្ពុជា

### កថាខណ្ឌ១៖ ការសិក្សាក្របខណ្ឌច្បាប់ និងបទពិសោធន៍បរទេសនៃការអនុវត្តពន្ធលើចំណេញមូលធន

**១. ប្រទេសម៉ាឡេស៊ី**

ប្រទេសម៉ាឡេស៊ី ត្រូវបានអនុវត្តពន្ធលើចំណេញមូលធន នៅក្នុងឆ្នាំ១៩៩៥[21] ។ ហើយចំពោះអត្រាប្រមូលពន្ធលើចំណេញមូលធននៅក្នុងប្រទេសនេះ គឺចំនួន ៣០% នៃចំណេញមូលធន។

ចំពោះការលើកលែងពន្ធនេះវិញ រូបវន្តបុគ្គលត្រូវបានផ្តល់អនុគ្រោះ ឲ្យដកពីចំណេញមូលធនជាប់ពន្ធនូវទឹកប្រាក់ ១០ ០០០ រីងហ្គីត (ប្រមាណជិត ១០ លានរៀល ) ឬ ដក ១០% ពីចំណេញមូលធន (យកជម្រើសណាដែលខ្ពស់ជាង )។ រូបវន្តបុគ្គលដែលមានសញ្ជាតិម៉ាឡេស៊ី ឬជានិវាសនជនអចិន្ត្រៃយ៍ ត្រូវបានលើកលែងតែម្តងគត់ក្នុងមួយជីវិត ចំពោះចំណេញមូលធនសម្រេចបានពីការផ្ទេរនិវាសនដ្ឋានឯកជនរបស់គាត់។ ការលើកលែងពន្ធចំពោះប្រតិបត្តិការត្រូវបានសន្មតថាស្មើនឹងថ្លៃដើមដូចជា៖ ការផ្ទេររវាងប្តី ប្រពន្ធ/ឪពុកម្តាយនិងកូនបង្កើត/យាយតា និងចៅបង្កើត អំណោយជូនរដ្ឋ ឬអាជ្ញាធរដែនដី ឬសម្បុរសធម៌ ជាដើម។ ចំពោះការផ្ទេរអចលនទ្រព្យដែលមានតម្លៃ ទាបជាង ២០០ ០០០ រីងហ្គីត (ប្រមាណជិត ២០០ លានរៀល ) (ទើបអនុវត្តចាប់បីឆ្នាំ២០១៩ ដោយច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩)។

[20] ច្បាប់សារពើពន្ធ លេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣,មាត្រា១២៧-១៣៥។

[21] បទបង្ហាញស្តីពី ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីប្រទេសកម្ពុជា របស់អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

**២. ប្រទេសកូរ៉េខាងត្បូង**

ប្រទេសកូរ៉េខាងត្បូង ត្រូវបានអនុវត្តពន្ធលើចំណេញមូលធន នៅក្នុងឆ្នាំ១៩៦០[22]។ ហើយចំពោះអត្រាប្រមូលពន្ធលើចំណេញមូលធន នៅក្នុងប្រទេសនេះ ៦% ដល់៣៨% បើកាលណាអ្នកកាន់កាប់មានរយៈពេលកាន់កាប់លើសពី ២ឆ្នាំឡើងទៅ។ ៤០% បើកាលណាអ្នកកាន់កាប់មានរយៈពេលកាន់កាប់ចាប់ពី ១ឆ្នាំដល់២ឆ្នាំ។៥០%បើរយៈពេលកាន់កាប់ក្រោម១ឆ្នាំ។

ចំពោះការលើកលែង ពន្ធលើចំណេញមូលធននេះវិញគឺ ចំពោះចំណេញមូលធនពីការលក់អចលទ្រព្យដែលបានពីសាលក្រមបញ្ជាក់ថាក្ស័យធន គឺត្រូវបានលើកលែង។ ចំណេញមូលធនពីការផ្ទេរផ្ទះស្នាក់នៅ ក្នុងតម្លៃកំណត់ចំណេញមូលធនពីការលក់ដីកសិកម្មដែលបានធ្វើរយៈពេលយ៉ាងហោចណាស់ ៨ឆ្នាំគឺត្រូវបានលើកលែង ហើយចំពោះចំណេញមូលធនរបស់កសិករពីការលក់ដីស្រែដើម្បីទិញដីស្រែផ្សេងទៀត ក៏ត្រូវបានលើកលែងដូចគ្នា ចំពោះពន្ធលើចំណេញមូលធន នៅក្នុងប្រទេសកូរ៉េខាងត្បូងនេះ។

**៣. ប្រទេសអូស្ត្រាលី**

ប្រទេសអូស្ត្រាលី ត្រូវបានអនុវត្តពន្ធលើចំណេញមូលធន នៅក្នុងឆ្នាំ១៩៨៥[23]។ ហើយចំពោះអត្រាប្រមូលពន្ធលើចំណេញមូលធន នៅក្នុងប្រទេសនេះ គឺជាប់ពន្ធតាមអត្រាពន្ធប្រាក់ចំណូលរូបវន្តបុគ្គល ចាប់ពី 0-៤៥%។

ចំពោះការលើកលែងនៅក្នុងការប្រមូលពន្ធលើចំណេញមូលធន នៅក្នុងប្រទេសនេះវិញ គឺនិវាសនដ្ឋានគោលដើម ទោចក្រយានយន្ត និងរថយន្ត ទ្រព្យសកម្មក្នុងអាជីវកម្មដែល អ្នកជាប់ពន្ធបានធ្វើការរំលស់ ទ្រព្យសកម្មដែលបានកាន់កាប់ មុនថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៨៥ ទ្រព្យប្រើប្រាស់ផ្ទាល់ខ្លួនមានតម្លៃ តិចជាង AUD ១០ 000 (ប្រមាណ ៧ ៣00 ដុល្លារអាមេរិក )។

**៤. ប្រទេសស៊ុយអ៊ែត**

ប្រទេសអូស្ត្រាលី ត្រូវបានអនុវត្តពន្ធលើចំណេញមូលធន នៅក្នុងឆ្នាំ១៩១០[24]។ ហើយចំពោះអត្រាប្រមូលពន្ធលើចំណេញមូលធន នៅក្នុងប្រទេសនេះ៣0% នៃចំណេញមូលធន ចំពោះរូបវន្តបុគ្គល និង ២១,៤% នៃចំណេញមូលធនចំពោះនីតិបុគ្គល។

[22] បទបង្ហាញស្តីពី ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីប្រទេសកម្ពុជា របស់អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

[23] បទបង្ហាញស្តីពី ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីប្រទេសកម្ពុជា របស់អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

[24] បទបង្ហាញស្តីពី ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីប្រទេសកម្ពុជា របស់អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

ចំពោះការលើកលែង នៅក្នុងការប្រមូលពន្ធលើចំណេញមូលធន នៅក្នុងប្រទេសនេះវិញគឺ លើកលែងពន្ធសម្រាប់អង្គភាពសាជីវកម្មស៊ុយអែត ស្តីពីការចំណេញទាក់ទងនិងការលក់ឬផ្ទេរភាគហ៊ុនសម្រាប់គោលបំណងពាណិជ្ជកម្ម និងលើកលែងភាគហ៊ុនដែលបានកាន់កាប់ក្នុងរយៈពេលយ៉ាងហោចណាស់មួយឆ្នាំ។

### ៥. ប្រទេសហ្វីលីពីន

ប្រទេសហ្វីលីពីន ត្រូវបានអនុវត្តពន្ធលើចំណេញមូលធន នៅក្នុងប្រហែល ៣ ទសវត្ស (១៩៩៤ តួរលេខចំណូលឆ្នាំដំបូងគេពី IMF) [25] ។ ហើយចំពោះអត្រាប្រមូលពន្ធលើចំណេញមូលធន នៅក្នុងប្រទេសនេះ ចំពោះអចលនទ្រព្យចែកនឹង ៦%នៃថ្លៃលក់សរុប ឬតម្លៃទីផ្សារដែលសមរម្យ (តម្លៃណាមួយដែលខ្ពស់ជាង) ចំពោះភាគហ៊ុន( ដែលមិនជួញដូរនៅក្នុងទីផ្សារភាគហ៊ុន)ចែក និង ដក១៥%ចំពោះសហគ្រាសក្នុងស្រុក ដក១៥% និង១០% ចំពោះសហគ្រាសក្រៅស្រុក ចំពោះមូលប័ត្រចែកនឹង 0.៦% គិតលើថ្លៃជួញដូរមូលប័ត្រ ចំពោះចំណេញមូលធនសហគ្រាស ចែកនឹង ៣២%(ក្របខណ្ឌពន្ធលើចំណូល)។

ចំពោះការលើកលែង នៅក្នុងការប្រមូលពន្ធលើចំណេញមូលធន នៅក្នុងប្រទេសនេះវិញគឺ ចំណេញមូលធនពីការលក់មូលធនបំណុល ការធានា ឬវិញ្ញាបនប័ត្រ ផ្សេងទៀតនៃបំណុលដែលមានកាលកំណត់លើសពីប្រាំឆ្នាំត្រូវបានរួចផុតពីពន្ធ។

### ៦. ប្រទេសថៃ

តាមរយៈបទបង្ហាញបទបង្ហាញ ស្តីពីការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីកម្ពុជា របស់អគ្គនាយកដ្ឋានពន្ធដារ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ បានបង្ហាញថា ចំពោះអត្រាប្រមូលពន្ធលើចំណេញមូលធននៅក្នុងប្រទេសថៃ ចំពោះរូបវន្តបុគ្គលជាផ្នែកមួយនៃពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល (៥%-៣៥%) ចំពោះនីតិបុគ្គលអនិវាសនជន១៥% និងនីតិបុគ្គនិវាសជន ២០%។

ចំពោះការលើកលែងពន្ធលើចំណេញមូលធននេះនៅក្នុងប្រទេសថៃវិញគឺត្រូវលើកលែងចំពោះ៖

- អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរដ្ឋ
- អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់ សហគមន៍ ឬបុគ្គលណាដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធ ខាងសាសនា និងសប្បុរសធម៌ដែលមិនមានគោលដៅស្វែងរកប្រាក់ចំណេញ

[25] បទបង្ហាញស្តីពី ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីប្រទេសកម្ពុជា របស់អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

- អចលនទ្រព្យដែលជាកម្មសិទ្ធរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស
- និវាសនដ្ឋានស្នាក់នៅជាគោលដើម ដែលរូវន្តបុគ្គលបានស្នាក់នៅ ក្នុងរយៈពេលជាប់ៗគ្នាយ៉ាងតិចបំផុត ៥ឆ្នាំ មុនការសម្រេចបានចំណេញមូលធន និងមានការបញ្ជាក់ពី ភាពត្រឹមត្រូវតាមច្បាប់ជាធរមានពីអាជ្ញាធរដែនដី ឬអាជ្ញាធរពាក់ព័ន្ធ
- អចលនទ្រព្យដែលមានរយៈពេលកាន់កាប់លើសពី៥០ឆ្នាំ។

## កថាខណ្ឌ២៖ ការដាក់ឲ្យអនុវត្តពន្ធលើចំណេញមូលធននៅកម្ពុជា

### ១. ក្របខណ្ឌគតិយុត្ត

**ពន្ធលើចំណេញមូលធន** នៅក្នុងប្រទេសកម្ពុជាត្រូវបានប្រកាសដាក់ឲ្យអនុវត្ត នៅក្នុងប្រទេសកម្ពុជាយើងនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ដោយយោងទៅតាមប្រកាសលេខ៣៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[26]។ ប៉ុន្តែពន្ធលើចំណេញមូលធននេះដដែលក៏ត្រូវបានពន្យារពេលនៅក្នុងការអនុវត្ត រហូតដល់បំណាច់ឆ្នាំ២០២១វិញដោយយោងទៅតាមសេចក្តីជូនដំណឹងលេខ២៤០៩៤ អ.ព.ដ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ស្តីពី **ការពន្យារកាលបរិច្ឆេទកំណត់ដាក់ឲ្យអនុវត្តពន្ធលើចំណេញមូលធន** [27] ដើម្បីទុកពេលវេលាគ្រប់គ្រាន់ដល់អ្នកជាប់ពន្ធ និងសាធារណៈជនទាំងអស់ដើម្បីស្វែងយល់អោយកាន់តែច្បាស់នូវបញ្ញត្តិនេះ។ ហើយគោលបំណងនៅក្នុងប្រកាសនេះមានគោលបំណងដាក់អនុវត្តពន្ធលើចំណេញមូលធន ដែលសម្រេចបានដោយអ្នកជាប់ពន្ធ ស្របតាមមាត្រា ៧ ថ្មី (មួយ) នៃច្បាប់សារពើពន្ធ។

ដោយផ្អែកលើការសិក្សាបទពិសោធន៍ពីបណ្តាប្រទេសនានា និងស្ថានភាពសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាពន្ធលើចំណេញមូលធន ត្រូវបានរៀបចំអនុវត្តដោយកំណត់ជាគោលការណ៏ពីរយ៉ាងគឺ ទី១គឺការកំណត់អត្រាគិតពន្ធ និងទី២ ការកំណត់នៅការលើកលែងពន្ធ។ ហើយចំពោះមូលធន ឬទ្រព្យដែលជាកម្មវត្ថុជាប់ ពន្ធលើចំណេញមូលធន រួមមាន អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយវត្ថុបរទេស ដែលទាំងអស់នេះសុទ្ធសឹងតែជាកម្មវត្ថុនៅក្នុងពន្ធលើចំណេញមូលធននេះ។

[26] ប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី ០១ មេសា ឆ្នាំ២០២០របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

[27] សេចក្តីជូនដំណឹងស្តីពីការពន្យាកាលបរិច្ឆេទកំណត់ដាក់ឲ្យអនុវត្តពន្ធលើចំណេញមូលធន លេខ២៤០៩៤ អពដ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ។

**២. អត្ថប្រយោជន៍**

ពន្ធលើចំណេញមូលធនមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការចូលរួមចំណែកក្នុងការបង្កើនចំណូលថវិការជាតិស្របតាមយុទ្ធសាស្ត្រគៀរចំណូល ២០១៩-២០២៣ ដើម្បីធានាបានចីរភាពនៃកំណើនចំណូល ចីរភាពនៃកំណើនសេដ្ឋកិច្ច ការប្រកួតប្រជែងដោយស្មើភាព និងសមធម៌សង្គម។ មួយវិញទៀតនៅក្នុងបរិបទនៃការរីករាតត្បាតជំងឺកូវីដ ១៩ ការប្រមូលពន្ធលើចំណេញមូលធននេះ នឹងបង្កើនជាប្រភពចំណូលមួយទៀតសម្រាប់ជួយដល់រាជរដ្ឋាភិបាល ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច និងគាំទ្រសង្គម នៅក្នុងបរិបទមួយដែលនៅក្នុងសេដ្ឋកិច្ចនៅលើពិភពលោកមានការធ្លាក់ចុះ។ ជាពិសេសលើសពីនេះទៅទៀតពន្ធលើចំណេញមូលធននេះ ក៏បានចូលរួមចំណែកយ៉ាងធំធេងនៅក្នុងការទប់ស្កាត់ទៅលើ រូបភាពនៃការចៀសវាងពន្ធតាមរយៈការទិញលក់អចលនទ្រព្យរបស់នីតិបុគ្គលក្នុងលក្ខណៈជារូបវន្តបុគ្គល ហើយដើម្បីធានាឲ្យបាននៅសមភាពរវាងរូបវន្តបុគ្គល និងនីតិបុគ្គល ព្រមទាំងជំរុញការវិនិយោគផងដែរ។ ពន្ធលើចំណេញមូលធននេះត្រូវបានចាត់ទុកថាជាវិធានការសារពើពន្ធរបស់រដ្ឋាភិបាល ដើម្បីគ្រប់គ្រងសកម្មភាពបរិកប្បកម្មលើអចលនទ្រព្យ (To control real estate speculation ) និងរក្សាស្ថេរភាពថ្លៃនៃអចលទ្រព្យ។ ចំពោះអ្នកអភិវឌ្ឍលំនៅដ្ឋានដែលបានចុះបញ្ជីជានីតិបុគ្គល និងបានបំពេញកាតព្វកិច្ចសារពើពន្ធរួចរាល់ហើយ គឺចំណេញមូលធន ត្រូវបានគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធក្នុងក្របខណ្ឌនៃពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ការប្រមូលពន្ធនេះ ក៏មានការគិតគូពីប្រជាពលរដ្ឋ ដែលមានអចលនទ្រព្យតិចតួច ដោយផ្តល់ការលើកលែងពន្ធចំពោះការលក់ ឬផ្ទេរនិវាសនដ្ឋានជាគោលដើម និងការផ្ទេរអចលនទ្រព្យនៅក្នុងរង្វង់ញាតិ។[28]

**៣.បញ្ហាប្រឈម និងដំណោះស្រាយ**

**ក-បញ្ហាប្រឈម៖** ដោយសារតែពន្ធលើចំណេញមូលធននេះ ផ្តោតសំខាន់លើរូបវន្តបុគ្គលដែលជាប្រជាពលរដ្ឋទូទៅ ហេតុនេះវាអាចមានបញ្ហាប្រឈមមួយចំនួននៅពេលដែលយើងដាក់ឲ្យអនុវត្តដូចជា ការមិនសូវយល់ច្បាស់អំពីប្រភេទពន្ធនេះ ដោយអ្នកជាប់ពន្ធ ការយល់ដឹងមានកម្រិតរបស់អ្នកជាប់ពន្ធលើបែបបទនិងនីតិវិធីនៃការដាក់លិខិតប្រកាស។

**ខ-ដំណោះស្រាយ៖** ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងអស់នេះ អគ្គនាយកដ្ឋានពន្ធដារ ផ្តោតសំខាន់លើការរៀបចំផែនការផ្សព្វផ្សាយ និងណែនាំបទប្បញ្ញត្តិស្តីពីពន្ធលើចំណេញមូលធន ឲ្យបានទំលំទូលាយដល់សាធារណៈជននិងអ្នកជាប់ពន្ធ ជ្រាបតាមរយៈការផ្សព្វផ្សាយប្រកាសស្តីអំពីពន្ធលើចំណេញមូលធន តាមរយៈគេហទំព័រ (GDT Website) ឬបណ្តាញទំនាក់ទំនងសង្គម (Facebook) នៃអគ្គនាយកដ្ឋានពន្ធដារ និងបណ្តាញ

[28] បទបង្ហាញស្តីពី ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីប្រទេសកម្ពុជា របស់អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

ព័ត៌មានផ្សេងៗ វីដេអូឃ្លីបពាក់ព័ន្ធនិងការបង់ពន្ធ លើចំណេញមូលធន ផ្សាយផ្ទាល់អំពីកម្មវិធីពន្ធដារ (GDT Live Show) ស្តីអំពីការប្រកាសស្តីពីពន្ធលើចំណេញមូលធន និងវេទិកាសំណួរ-ចម្លើយតាមរយៈ Live Chat និង Call Center និងរៀបចំសេចក្តីណែនាំបន្ថែមស្តីពីការដាក់លិខិតប្រកាស និងបង់ពន្ធលើចំណេញមូលធន រៀបចំសិក្ខាសាលា ជូនដល់អ្នកជាប់ពន្ធនៅតាម រាជធានី-ខេត្ត រៀបចំវគ្គបណ្តុះបណ្តាល ជូនមន្ត្រីពន្ធដារនៅតាមរាជធានី-ខេត្ត បញ្ចូលមេរៀន ស្តីពីពន្ធលើចំណេញមូលធនក្នុងកម្មវិធីវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ នៅសាលាជាតិពន្ធដារ។[29]

[29] បទបង្ហាញស្តីពី ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីប្រទេសកម្ពុជា របស់អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

# ជំពូកទី២

# វិធាន និងនីតិវិធីគ្រប់គ្រងពន្ធលើ
# ចំណេញមូលធននៅកម្ពុជា

# ជំពូកទី២
# វិធាន និងនីតិវិធីគ្រប់គ្រងពន្ធលើចំណេញមូលធននៅកម្ពុជា
## ផ្នែកទី១៖ កម្មវត្ថុនៃពន្ធ អត្រាពន្ធ និងការគណនាពន្ធ
### កថាខណ្ឌ១៖ និយមន័យ និងកម្មវត្ថុនៃពន្ធ
#### ១.និយមន័យ

**ក- អ្នកជាប់ពន្ធ៖** សំដៅដល់អ្នកជាប់ពន្ធនិវាសនជន ដែលបានលក់ ឬផ្ទេរមូលធនទៅឲ្យបុគ្គលដទៃ។

**ខ-អ្នកជាប់ពន្ធនិវាសនជន៖** សំដៅដល់រូបវន្តបុគ្គលណាម្នាក់ដែលមានលក្ខណៈវិនិច្ឆ័យចាប់ពីមួយឡើងទៅក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងបីដូចខាងក្រោម៖

- មាននិវាសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មសិទ្ធិ ឬជួល ឬភតិសន្យា ផ្ទះ អាគារ បន្ទប់ជួល អន្តេវាសិកដ្ឋាន។ល។ ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះតែងតែស្នាក់នៅ ឬកាន់កាប់។
- មានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរូបភាពជាក់ស្តែងនៃការស្នាក់នៅដោយផ្អែកទៅលើកត្តានានាដូចជា មជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល រយៈពេលស្នាក់នៅ ចរិតនៃការស្នាក់នៅ ទីកន្លែងដែលគ្រួសាររបស់រូបវន្តបុគ្គលនោះស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល ទីកន្លែងដែលរូបវន្តបុគ្គលធ្វើសកម្មភាពសង្គមជាសំខាន់។
- មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២ថ្ងៃក្នុងមួយលើក ឬច្រើនលើក ក្នុងរយៈពេល១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅនៅព្រះរាជាណាចក្រកម្ពុជា វត្តមានក្នុងចំណែកណាមួយនៃថ្ងៃត្រូវរាប់ថាជា១ថ្ងៃពេញ។

ក្នុងករណីដែលមានភាពមិនច្បាស់លាស់ក្នុងការវិនិច្ឆ័យតាមលក្ខខណ្ឌដែលមានចែងក្នុងចំណុចទី១ និងចំណុចទី២ ខាងលើនេះ វត្តមានរបស់រូបវន្តបុគ្គលដែលមានចែងក្នុងចំណុចទី៣ គឺជាលក្ខខណ្ឌចុងក្រោយសម្រាប់កំណត់ភាពជានិវាសនជនរបស់រូបវន្តបុគ្គល។

**គ- អ្នកជាប់ពន្ធអនិវាសនជន៖** គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន។

**ឃ-មូលធន៖** សំដៅដល់អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា រូបិយវត្ថុបរទេស។

**ង- ចំណេញមូលធន៖** សំដៅដល់ប្រាក់ចំណូលជាប់ពន្ធដែលបានពីការយកចំណូលពីការលក់ ឬផ្ទេរមូលធន ដកការកាត់កងចំណាយដែលអនុញ្ញាត។[30]

### ២. កម្មវត្ថុនៃពន្ធ

#### ២.១. ដែនវិសាលភាពនៃពន្ធលើចំណេញមូលធន

**មូលធន ឬទ្រព្យ** ដែលជាកម្មវត្ថុជាប់ពន្ធលើចំណេញមូលធនមាន០៦ប្រភេទគឺ៖

- **អចលនទ្រព្យ៖** សំដៅដល់ដី ផ្ទះ អាគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ ស្របតាមបទបញ្ញត្តិស្តីពីពន្ធលើអចលនទ្រព្យ។
- **ភតិសន្យា៖** សំដៅដល់ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឲ្យកាន់កាប់ និងប្រើប្រាស់អចលនវត្ថុក្នុងរយៈពេលមួយដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬតាមតម្លៃសមមូល។ ភតិសន្យារួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ វៀរលែងតែភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុ និងភតិសន្យាពិសេសដែលមានចែងក្នុងច្បាប់ស្តីពីភតិសន្យាពិសេស។
- **ទ្រព្យវិនិយោគ៖** សំដៅដល់ភាគហ៊ុន សញ្ញាប័ណ្ណ និងមូលប័ត្រ ដែលបោះផ្សាយដោយសហគ្រាសឯកជន។
- **កេរ្តិ៍ឈ្មោះអាជីវកម្ម៖** សំដៅដល់អាជ្ញាប័ណ្ណ បញ្ជីឈ្មោះអតិថិជន និងយីហោ។
- **កម្មសិទ្ធិបញ្ញា៖** រួមមានតក្កកម្ម ស្នាដៃអក្សរសាស្ត្រ និងសិល្បៈ និមិត្តសញ្ញា រូបភាពនិងគំនូរ ដែលត្រូវបានប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម។
- **រូបិយវត្ថុបរទេស៖** សំដៅដល់រូបិយប័ណ្ណក្រៅពីប្រាក់រៀល។

សម្រាប់គោលដៅនៃប្រកាសស្តីពីពន្ធលើចំណេញមូលធននេះ អ្នកជាប់ពន្ធសម្រេចបានចំណេញមូលធន នៅពេលលក់ ឬផ្ទេរ ឬបង្កើតឲ្យមានសិទ្ធិគ្រប់គ្រងលើទ្រព្យ ឬចុះបញ្ជីសម្រាប់ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិនៅអាជ្ញាធរមានសមត្ថកិច្ច ឬពេលសម្រេចផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ទ្រព្យដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។[31]

[30] ប្រការ៤ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[31] ប្រការ៦ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ២.២. ការលើកលែងពន្ធលើចំណេញមូលធន

ពន្ធលើចំណេញមូលធន ត្រូវបានលើកលែងចំពោះការលក់ ឬផ្ទេរទ្រព្យ ដែលជាកម្មសិទ្ធិរបស់រដ្ឋ។ ទ្រព្យ ដែលជាកម្មសិទ្ធិរបស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃ។ និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធ ដែលបានកាន់កាប់ក្នុងរយៈពេលយ៉ាងតិច៥ (ប្រាំ) ឆ្នាំមុន ពេលលក់ ឬផ្ទេរ។ ក្នុងករណីអ្នកជាប់ពន្ធមាននិវាសនដ្ឋានច្រើនជាងមួយ ឬអ្នកជាប់ពន្ធ និងសហព័ទ្ធមាននិវាសនដ្ឋានផ្សេងពីគ្នា និវាសនដ្ឋានតែមួយប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតជានិវាសនដ្ឋានជាគោលដើម។អចលនវត្ថុក្នុងវង្សញាតិ ដូចមានចែងក្នុងបទប្បញ្ញត្តិស្ដីពីពន្ធប្រថាប់ត្រា វៀរលែងតែការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងបងប្អូនបង្កើត និងបងប្អូនបង្កើត រវាងឪពុក-ម្ដាយក្មេក និងកូនប្រសារ និងរវាងយាយតាក្មេក និងចៅប្រសារ។ ទ្រព្យ ដែលត្រូវបានលក់ ឬផ្ទេរដើម្បីបម្រើប្រយោជន៍សាធារណៈស្របតាមច្បាប់ស្ដីពីអស្សាមិករណ៍។[32]

### កថាខណ្ឌ២៖ អត្រាពន្ធ មូលដ្ឋានគិតពន្ធ និងការគណនាពន្ធ

#### ១. អត្រាពន្ធ មូលដ្ឋានគិតពន្ធ

អត្រាពន្ធ ត្រូវកំណត់ដោយអត្រាថេរ ២០%។[33]

**មូលដ្ឋានគិតពន្ធ** គឺជាចំណេញមូលដ្ឋាន ដែលជាប្រាក់ចំណូលជាប់ពន្ធបានពីការយកចំណូលពីការលក់ ឬផ្ទេរមូលធន ដកការកាត់កងចំណាយដែលអនុញ្ញាត ឬថ្លៃដើមនៃទ្រព្យ។

**តាមរូបមន្ត៖**

**ចំណេញមូលធន = ថ្លៃលក់ ឬផ្ទេរនៃទ្រព្យ - ថ្លៃដើមនៃទ្រព្យ**

[32] ប្រការ៥ នៃប្រកាសស្ដីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[33] ប្រការ១០ នៃប្រកាសស្ដីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីគណនាពន្ធលើចំណេញមូលធន ថ្លៃលក់ និងថ្លៃដើមនៃទ្រព្យ ត្រូវកំណត់ដូចខាងក្រោម៖

- **ថ្លៃលក់នៃទ្រព្យ** ត្រូវគិតតាមតម្លៃលក់ ឬផ្ទេរទ្រព្យដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាទិញ-លក់ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធរកឃើញថាថាថ្លៃលក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាទិញ-លក់ មានតម្លៃទាបជាងតម្លៃទីផ្សារ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ឡើងវិញនូវថ្លៃលក់នៃទ្រព្យ ដោយឈរលើតម្លៃទីផ្សារ ឬតម្លៃដែលកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬតម្លៃដែលកំណត់ដោយគណៈកម្មការវាយតម្លៃទ្រព្យនៃពន្ធលើចំណេញមូលធន។
- **ថ្លៃដើមនៃទ្រព្យ** រួមមានថ្លៃដើមពេលទិញទ្រព្យ និងចំណាយដែលបានកើតឡើងក្នុងពេលទិញ ឬទទួលកាន់កាប់លក់ ឬផ្ទេរទ្រព្យ ដែលជាអាទិ៍មាន៖

ក. ចំណាយលើសេវាពិគ្រោះយោបល់

ខ. ប្រាក់ពន្ធប្រថាប់ត្រាដែលបានបង់នៅពេលទិញ ឬទទួលទ្រព្យ

គ. ប្រាក់ពន្ធលើអចលនទ្រព្យ ឬប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលបានបង់

ឃ. ចំណាយលើសេវារដ្ឋបាលសុរិយោដី ឬភូមិបាល

ង. ចំណាយលើការផ្សព្វផ្សាយពាណិជ្ជកម្ម

ច. ចំណាយកម្រៃជើងសា

ឆ. ចំណាយលើការវាយតម្លៃទ្រព្យ

ជ. ចំណាយលើសេវារដ្ឋបាលចំពោះការខ្ចីប្រាក់ដើម្បីទិញ ឬទទួលទ្រព្យ

ឈ. ចំណាយការប្រាក់ចំពោះការខ្ចីប្រាក់ដើម្បីទិញទ្រព្យដែលបានបង់ក្នុងអំឡុងពេលកាន់កាប់ទ្រព្យ

ញ. ចំណាយថែទាំ និងកែលម្អទ្រព្យ

ដ. ចំណាយក្នុងការបង្កើត ឬក្សាការពារនូវសិទ្ធិកាន់កាប់ទ្រព្យ។[34]

## ២. ការគណនាពន្ធ

### ២.១. វិធីសាស្ត្រនៃការគណនា

ពន្ធលើចំណេញមូលធន ត្រូវបានគណនាដោយយកចំណេញមូលធន គុណនឹងអត្រាពន្ធដូចដែលមានចែងក្នុងប្រការ១០ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន។

[34] ប្រការ៩ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**តាមរូបមន្ត៖**

**ពន្ធលើចំណេញមូលធន = មូលដ្ឋានគិតពន្ធ × អត្រាពន្ធ (២០%)**

### ២.២. វិធាននៃការកាត់កងចំណាយ

វិធាននៃការកាត់កងចំណាយត្រូវកំណត់៖

#### ២.២.១.មូលធនជាអចលនទ្រព្យ

អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឲ្យជ្រើសរើសវិធីណាមួយក្នុងចំណោមវិធីទាំងពីរដូចខាងក្រោម៖

**+វិធីកាត់កងចំណាយតាមការកំណត់៖** ត្រូវបានអនុញ្ញាតឲ្យធ្វើការកាត់កងចំណាយ ៨០ ភាគរយនៃប្រាក់ចំណូលដែលទទួលបានពីការលក់ ឬផ្ទេរទ្រព្យ។

**+វិធីកាត់កងតាមចំណាយជាក់ស្តែង៖** ត្រូវបានអនុញ្ញាតឲ្យធ្វើការកាត់កងចំណាយ ដែលបានកើតឡើងជាក់ស្តែង។[35]

**+ វិធីកាត់កងចំណាយតាមការកំណត់៖**

**ឧទាហរណ៍ (អចលនវត្ថុ)៖**

លោក **ក** លក់ផ្ទះទៅឲ្យលោក **ខ** ក្នុងតម្លៃ **៨០០លានរៀល** ដោយមិនបានរក្សាឯកសារចំណាយនានា។ ដូចនេះលោក **ក** ជ្រើសរើសវិធីកាត់កងចំណាយតាមការកំណត់ ដើម្បីគណនាពន្ធលើចំណូលមូលធន។

| | | | | |
|---|---|---|---|---|
| **គណនាថ្លៃដើមនៃទ្រព្យ** | = | ថ្លៃលក់ ឬផ្ទេរនៃទ្រព្យ | × | ៨០% |
| | = | ៨០០លាន | × | ៨០% |
| | = | ៦៤០ លានរៀល | | |
| **គណនាចំណេញមូលធន** | = | ថ្លៃលក់ ឬផ្ទេរនៃទ្រព្យ | – | ថ្លៃដើមនៃទ្រព្យ |
| | = | ៨០០លាន | – | ៦៤០លាន |
| | = | ១៦០ លានរៀល | | |

[35] ប្រការ៨ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គណនាពន្ធលើចំណេញមូលធន** = ចំណេញមូលធន × ២០%
= ១៦០លាន × ២០%
= ៣២លានរៀល

**+ វិធីកាត់កងចំណាយតាមការជាក់ស្តែង៖**

**ឧទាហរណ៍ (អចលនវត្ថុ)**

លោក **ក** លក់ផ្ទះទៅឲ្យលោក **ខ** ក្នុងតម្លៃ **៦០០លានរៀល** ដែលលោកទិញក្នុងតម្លៃ **៤០០លានរៀល**។ លោកបានបង់ពន្ធប្រថាប់ត្រាលើអចលនទ្រព្យ **១៦លានរៀល** បានចំណាយកម្រៃជើងសាសម្រាប់លក់ផ្ទះ **២៤លានរៀល** និងចំណាយជួសជុល **២០លានរៀល**។ លោក **ក** បានរក្សាទុកឯកសារចំណាយពាក់ព័ន្ធទាំងអស់។

**គណនាថ្លៃដើមនៃទ្រព្យ** = ថ្លៃដើម + ប្រាក់ពន្ធបានបង់ + ចំណាយកម្រៃជើងសា + ចំណាយកែលម្អ
= ៤០០លាន + ១៦លាន + ២៤លាន + ២០លាន
= ៤៦០លានរៀល

**គណនាចំណេញមូលធន** = ថ្លៃលក់ ឬផ្ទេរទ្រព្យ − ថ្លៃដើមនៃទ្រព្យ
= ៦០០លាន − ៤៦០លាន
= ១៤០លានរៀល

**គណនាពន្ធលើចំណេញមូលធន** = ចំណេញមូលធន × ២០%
= ១៤០លាន × ២០%
= ២៨លានរៀល

**ឧទាហរណ៍ (ភតិសន្យា)**

លោក **ខ** បានទិញភតិសន្យាលើអចលនទ្រព្យនៅឆ្នាំ២០២០ សម្រាប់រយៈពេល១០ឆ្នាំ ក្នុងតម្លៃ **៣០០លានរៀល**។ នៅឆ្នាំ២០២២ លោក **ខ** បានលក់ភតិសន្យាលើអចលនទ្រព្យនេះទៅឲ្យលោក **គ** ក្នុងតម្លៃ **៤០០លានរៀល**។ លោក **ខ** បានចំណាយលើការជួសជុលបន្ថែមអស់ចំនួន **២០លានរៀល**។

**គណនាចំណេញមូលធន** = ថ្លៃលក់ ឬផ្ទេរនៃទ្រព្យ − (ថ្លៃដើម + ចំណាយអនុញ្ញាតឲ្យកាត់កង)
= ៤០០លានរៀល − (៣០០លាន + ២០លាន)
= ៨០លានរៀល

**គណនាពន្ធលើចំណេញមូលធន** = ចំណេញមូលធន × ២០%
= ៨០លាន × ២០%

= ១៦លានរៀល

**ឧទាហរណ៍ (ទ្រព្យវិនិយោគ-ភាគហ៊ុន)**

លោក **ក** បានទិញភាគហ៊ុនក្រុមហ៊ុន **ខ** ក្នុងតម្លៃ **១០០ដុល្លារ** ក្នុងមួយភាគហ៊ុន។ លោក **ក** បានលក់ភាគហ៊ុននេះវិញទៅឲ្យលោក **គ** ក្នុងតម្លៃ **១៥០ដុល្លារ** ក្នុងមួយភាគហ៊ុន។

**គណនាចំណេញមូលធន** = ថ្លៃលក់ ឬផ្ទេរនៃទ្រព្យ − (ថ្លៃដើម + ចំណាយអនុញ្ញាតឲ្យកាត់កង)

= ១៥០ − ១០០

= ៥០ដុល្លារ

**គណនាពន្ធលើចំណេញមូលធន** = ចំណេញមូលធន × ២០%

= ៥០ × ២០%

= ១០ដុល្លារ

**ឧទាហរណ៍ (រូបិយវត្ថុបរទេស)**

លោក **ក** បានទិញលុយអឺរ៉ូទុកចំនួន **២០ ០០០អឺរ៉ូ** ដោយចំណាយអស់ **២២ ០០០ដុល្លារ** (១អឺរ៉ូ =១,១ ដុល្លារ)។១ខែក្រោយមកគាត់បានលក់ចេញលុយអឺរ៉ូនៅពេលឡើងថ្លៃបានចំនួន**២៤០០០ដុល្លារ** (១អឺរ៉ូ = ១,២ ដុល្លារ) ដោយបានចំណាយជាទឹកប្រាក់មានចំនួន **២០០០ដុល្លារ**។

**គណនាចំណេញមូលធន** = ថ្លៃលក់ ឬផ្ទេរនៃទ្រព្យ − (ថ្លៃដើម + ចំណាយអនុញ្ញាតឲ្យកាត់កង)

= ២៤ ០០០ − ២២ ០០០

= ២០០០ដុល្លារ

### ២.២.២. មូលធនដទៃទៀត

អនុញ្ញាតឲ្យកាត់កងតាមចំណាយជាក់ស្តែងប៉ុណ្ណោះ។

**សម្គាល់៖** ករណីចំណាយជាក់ស្តែង មានចំនួនច្រើនជាងចំណូលពីការលក់ ឬផ្ទេរទ្រព្យ នោះចំនួនដែលលើសមិនត្រូវបានអនុញ្ញាតឲ្យបង្វិលសង ឬកាត់កងនឹងចំណូលមូលធននៃទ្រព្យដទៃទៀតទេ។

## ៣. ពន្ធលើចំណេញមូលធនចំពោះទ្រព្យនៅក្រៅព្រះរាជាណាចក្រកម្ពុជា

ក្នុងករណីដែលអ្នកជាប់ពន្ធនិវាសនជន ទទួលបានចំណេញមូលធនពីទ្រព្យណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងបានបង់ពន្ធលើចំណេញមូលធនតាមច្បាប់ពន្ធដារបរទេសរួចហើយ ប្រសិនបើប្រាក់ពន្ធនៅ

បរទេសនោះ មានចំនួនតិចជាងប្រាក់ពន្ធដែលគណនាតាមប្រការ១២ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធននេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមតែចំនួនលម្អៀងប៉ុណ្ណោះ។[36]

## ផ្នែកទី២៖ ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

### កថាខណ្ឌ១៖ ការដាក់លិខិតប្រកាស និងការបង់ពន្ធ

ក- កាតព្វកិច្ច របស់អ្នកជាប់ពន្ធ៖ អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធនិងដាក់លិខិតប្រកាសសារពើពន្ធ ដោយផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ។ ជាពិសេសអ្នកជាប់ពន្ធត្រូវបង់ពន្ធតាមកាលបរិច្ឆេទកំណត់ បើពុំដូច្នេះទេនោះនឹងត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធជាធរមានផងដែរ។ កាតព្វកិច្ចចម្បងរបស់អ្នកជាប់ពន្ធនោះ គឺត្រូវបង្ហាញនូវឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ ដូចជាបញ្ជីលិខិតយុត្តិការជាដើម ដោយត្រូវកាន់កាប់ និងថែរក្សាដោយផ្ទាល់។ ម្យ៉ាងទៀតនោះ អ្នកជាប់ពន្ធត្រូវមានវត្តមានបង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធ តាមកាលបរិច្ឆេទដែលមានចុះនៅក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។ ក្នុងករណីពិសេសនោះអ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗដែលរដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬដែលរដ្ឋបាលសារពើពន្ធក្នុងការបំពេញកាតព្វកិច្ច។

អ្នកជាប់ពន្ធ ត្រូវដាក់លិខិតប្រកាសពន្ធតាមទម្រង់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងបង់ពន្ធលើចំណេញមូលធន តាមប្រតិបត្តិការនីមួយៗជូនរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេលមិនលើសពី០៣ខែ បន្ទាប់ពីសម្រេចបានចំណេញមូលធនដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ។ ចំពោះទ្រព្យដែលស្ថិតនៅរាជធានីភ្នំពេញ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះទ្រព្យដែលស្ថិតនៅតាមបណ្តាខេត្ត អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅសាខាពន្ធដារខេត្តដែលទ្រព្យស្ថិតនៅ។[37]

ខ-សិទ្ធិ របស់អ្នកជាប់ពន្ធ៖ អ្នកជាប់ពន្ធមានសិទ្ធិទទួលបានការរក្សាទុកជាការសម្ងាត់នូវរាល់ព័ត៌មានដែលអ្នកជាប់ពន្ធបានផ្តល់ជូនរដ្ឋបាលសារពើពន្ធ និងទទួលបានការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈដោយមានការជួយពន្យល់ណែនាំឲ្យបានយល់អំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ នីតិវិធីសារពើពន្ធ ការអនុវត្តកាតព្វកិច្ចសារពើ

[36] ប្រការ១៣ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[37] ប្រការ១៤ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ពន្ធ និងសេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ។ ជាពិសេសអ្នកជាប់ពន្ធអាចមានសិទ្ធិក្នុងការប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធបានផងដែរ។ មិនត្រឹមតែប៉ុណ្ណោះក៏បើកទូលាយឲ្យមានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ តាមការជ្រើសរើសដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ ដើម្បីបង្កភាពងាយស្រួលក្នុងការអនុវត្តផងដែរ។ ម្យ៉ាងទៀតអ្នកជាប់ពន្ធអាចទទួលបានការអនុវត្តដោយភាពស្មោះត្រង់ មានតម្លាភាព និងមិនលម្អៀងពីសំណាក់រដ្ឋបាលសារ ពើពន្ធ ដោយបង់ពន្ធមិនឲ្យលើសពីបទបញ្ញត្តិស្តីពីពន្ធដារកំណត់ឡើយ។

**កថាខណ្ឌ២៖ ឯកសារតម្រូវ**

អ្នកជាប់ពន្ធត្រូវផ្តល់នូវឯកសារពាក់ព័ន្ធ សម្រាប់ការបង់ពន្ធលើចំណេញមូលធន ដូចខាងក្រោម៖

ក- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស

ខ- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ

គ- លិខិតបញ្ជាក់របស់អ្នកជាប់ពន្ធ អំពីការកំណត់និវាសនដ្ឋានជាគោលដើមរបស់ខ្លួន

ឃ-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន ដែលចេញដោយរដ្ឋបាល សុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ-សង្កាត់ឡើងទៅ ឬឯកសារបញ្ជាក់ការទទួលស្គាល់របស់ស្ថាប័នមានសមត្ថកិច្ច

ង- កិច្ចសន្យាទិញ-លក់ទ្រព្យ ឬកិច្ចសន្យាដោះដូរ ឬអំណោយ

ច- វិក្កយបត្រទូទាត់ប្រាក់និងវិក្កយបត្រចំណាយផ្សេងៗដូចមានចែងក្នុងប្រការ៩នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន

ឆ- ឯកសារដទៃទៀតពាក់ព័ន្ធនឹងការលក់ ឬផ្ទេរមូលធន។[38]

**កថាខណ្ឌ៣៖ ទោសបញ្ញត្តិ**

អ្នកជាប់ពន្ធត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធជាធរមាន ក្នុងករណីមិនបានដាក់លិខិតប្រកាស និងបង់ពន្ធលើចំណេញមូលធនតាមពេលកំណត់។[39]

---

[38] ប្រការ១៥ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[39] ប្រការ១៩ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធិភាពតាមភារកិច្ចរៀងៗខ្លួន។[40]

[40] ប្រការ២០ នៃប្រកាសស្តីពីពន្ធលើចំណេញមូលធន លេខ៣៤៦ សហវ.ប្រក ចុះថ្ងៃទី០១ មេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវប្រធានបទស្តីពី **ពន្ធលើចំណេញមូលធន** រួចមក ក្រុមរបស់យើងខ្ញុំសង្កេតឃើញថាប្រធានបទខាងលើនេះ គឺជារបបគតិយុត្តមួយដែលថ្មីស្រឡាង និងដែលមានលក្ខណៈស្មុគស្មាញផងដែរ សម្រាប់មជ្ឈដ្ឋានទូទៅ។ ហេតុដូចនេះ ការសិក្សាស្រាវជ្រាវអំពីប្រធានបទនេះ គឺក្រុមរបស់យើងខ្ញុំមានគោលបំណងចង់ផ្តោតទៅលើលក្ខខណ្ឌសំខាន់ៗមួយចំនួន និងការអនុវត្តសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ដើម្បីធ្វើយ៉ាងណាបង្កជាភាពងាយស្រួលសម្រាប់មជ្ឈដ្ឋានទូទៅក្នុងការសិក្សា និងស្វែងយល់។

តួយ៉ាងសារណានេះផ្តោតទៅលើផ្នែកសំខាន់ៗមានដូចជា នៅត្រង់ចំណុចនៃជំពូកទី១ បកស្រាយអំពីទិដ្ឋភាពទូទៅនៃប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះនឹងធ្វើការបញ្ជាក់អំពីការវិវត្តនៃច្បាប់ពន្ធដារ រចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារ ទ្រឹស្តីទូទៅនៃពន្ធដារ ជាពិសេសការសិក្សាអំពីក្របខណ្ឌច្បាប់ និងបទពិសោធន៍នៃការអនុវត្តពន្ធលើចំណេញមូលធននេះ មិនត្រឹមតែក្នុងមជ្ឈដ្ឋានក្នុងប្រទេសទេ ក៏ប៉ុន្តែក្រុមរបស់យើងខ្ញុំបានបន្ថែមទាំងករណីបរទេសមួយចំនួនបញ្ចូលថែមទៀតផងដែរ។ ចំណែកនៅក្នុងចំណុចនៃជំពូកទី២ នឹងធ្វើការបកស្រាយលំអិតអំពីវិធាន និងនីតិវិធីគ្រប់គ្រងពន្ធលើចំណេញមូលធននៅកម្ពុជាដែលក្នុងនោះសង្កត់ធ្ងន់និងផ្តោតទៅលើនិយមន័យកម្មវត្ថុនៃពន្ធ អត្រាពន្ធ មូលដ្ឋានគិតពន្ធ និងរបៀបនៃការគណនាពន្ធផងដែរ។ ជាងនេះទៅទៀតនោះគឺសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធពិតជាមានសារៈប្រយោជន៍ណាស់ ដែលយើងខ្ញុំនឹងធ្វើការបកស្រាយជូន។

ស្របពេលជាមួយគ្នានេះដែរ យើងបានដឹងហើយថាប្រទេសយើងជាប្រទេសកំពុងអភិវឌ្ឍន៍ ជាហេតុនាំឲ្យ មានប្រជាជនភាគច្រើនមិនទាន់យល់នូវអំពីប្រព័ន្ធពន្ធដារថ្មីនេះនៅកម្ពុជាច្បាស់លាស់នៅឡើយទេ ហើយខ្វះខាតក្នុងការទទួលយកនូវចំណេះដឹងពីសិទ្ធិ និងកាតព្វកិច្ចដែលពាក់ព័ន្ធជាមួយនឹងប្រព័ន្ធពន្ធដារខាងលើនេះផងដែរ។

ដូច្នេះដើម្បីបញ្ចៀសនូវបញ្ហាទាំងអស់នេះ រាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចគួរគប្បីធ្វើការផ្សព្វផ្សាយអំពីប្រព័ន្ធពន្ធដារថ្មី និងពន្យារពេលវេលាក្នុងការអនុវត្តនីតិវិធី ឬវិធានផ្សេងៗ ជូនប្រជាពលរដ្ឋ ដើម្បីឲ្យប្រជាពលរដ្ឋយល់ដឹងពីបញ្ហានេះ និងជៀសវាងក្នុងការអនុវត្តខុសនីតិវិធីច្បាប់ផ្សេងៗផងដែរ។

# អនុសាសន៍

ទោះបីជាយុទ្ធសាស្ត្រគៀគរចំណូលឆ្នាំ២០១៩-២០២៣ ដែលបាននឹងកំពុងដាក់ឲ្យអនុវត្ត និងមានប្រសិទ្ធភាពយ៉ាងណាក៏ដោយក៏ប៉ុន្តែតម្រូវការនៃការអភិវឌ្ឍន៍របស់ប្រទេសជាតិក៏មានកំណើនខ្ពស់ផងដែរ ដែលតម្រូវឲ្យរាជរដ្ឋាភិបាលគួតែដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀត ដើម្បីអាចមានប្រភពចំណូលកើនឡើងបន្ថែមនឹងបំពេញនូវគ្រប់តម្រូវការនានាដើម្បីឆ្លើយតបនៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ យ៉ាងណាក្តីថ្មីៗនេះមានពន្ធមួយប្រភេទដែលត្រូវបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសេចក្តីប្រកាសដាក់ចេញដើម្បីអនុវត្តនៅក្នុងខែមេសា ឆ្នាំ២០២០ ប៉ុន្តែដោយសារមានការឆ្លងរីករាលដាលជាសកលនូវជំងឺកូវីដ-១៩ ទើបអគ្គនាយកដ្ឋានពន្ធដារ ដែលជាសេនាធិការបស់រាជរដ្ឋាភិបាលដែលមានទូនាទីប្រមូលពន្ធចូលទៅក្នុងថវិកាជាតិបានសម្រេចចិត្តពន្យាពេលនៅក្នុងការអនុវត្តរហូតទៅដល់បំណាច់ឆ្នាំ២០២១វិញ។

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ទៅលើប្រធានបទ **ពន្ធលើចំណេញមូលធន** នេះរួចមកយើងខ្ញុំទាំងពីរនាក់បានស្វែងយល់ឃើញអំពីសារៈសំខាន់នៃពន្ធលើចំណេញមូលធន នេះយ៉ាងខ្លាំងនៅក្នុងការជួយអភិវឌ្ឍន៍ប្រទេសជាតិ បើទោះបីជាពន្ធលើចំណេញមូលធន នេះត្រូវបានពន្យារពេលនៅក្នុងការដាក់អោយអនុវត្តនៅក្នុងប្រទេសកម្ពុជាយើងយ៉ាងណាក៏ដោយ។ នាថ្ងៃអនាគតពន្ធនេះនិងក្លាយទៅជាប្រភេទពន្ធមួយ ដែលនឹងអាចប្រមូលពន្ធជូនរដ្ឋបានយ៉ាងច្រើនសម្រាប់ជួយទ្រទ្រង់ប្រទេសជាតិទៅលើគ្រប់វិស័យ ដោយហេតុថាពន្ធលើចំណេញមូលធននេះ គឺជាប្រភេទពន្ធដែលមានកម្មវត្ថុប្រមូលទៅលើប្រភេទ អចលនវត្ថុ ភតិសន្យា ទ្រព្យវិនយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម រូបិយវត្ថុបរទេស កម្មសិទ្ធិបញ្ញា ស្របពេលដែលកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃកំពុងមានការកើនឡើងយ៉ាងខ្លាំងក្លានៅក្នុងរយៈពេលចុងក្រោយនេះ ខណៈពេលដែលគ្រប់វិស័យទាំងអស់ក៏កំពុងមានការកើនឡើងជាលំដាប់ ជាពិសេសវិស័យអចលនទ្រព្យ និងសំណង់។ ប៉ុន្តែទោះបីជាមើលឃើញពីសារៈប្រយោជន៍របស់ពន្ធលើចំណេញមូលធននេះយ៉ាងណាក្តីក៏យើងមិនអាចសន្មតថានិងអាចប្រមូលពន្ធបាន១០០%ផងដែរ។ ហេតុដូច្នេះហើយអគ្គនាយកដ្ឋានពន្ធដារ ត្រូវតែផ្សព្វផ្សាយជូនដល់សាធារណៈជនឲ្យបានទូលំទូលាយអំពីប្រភេទពន្ធថ្មីនេះ ដើម្បីអោយបុគ្គលដែលមានកាតព្វកិច្ចជាប់ពន្ធទាំងអស់បានជ្រាបឲ្យកាន់តែច្បាស់ មួយវិញទៀតចំពោះផ្នែករដ្ឋបាលរបស់ខ្លួន ជាពិសេសការផ្តត់ផ្គង់សេវាសាធារណៈ ជូនទៅដល់បុគ្គលដែលមានកាតព្វកិច្ចជាប់ពន្ធទូទាំងប្រទេស គួរតែបម្រើអ្នកជាប់ពន្ធដោយរុះរាយរាក់ទាក់ ស្មោះត្រង់ និងប្រកបដោយវិជ្ជាជីវៈខ្ពស់និងមិនពុករលួយប្រកបដោយក្រមសីលធម៌។

# ឯកសារពិគ្រោះ

❖ **បទដ្ឋានគតិយុត្តច្បាប់**

- ក្រុមប្រឹក្សារដ្ឋ លេខ ២២ ក្រ.ប ក្រឹត្យច្បាប់ស្តីពីពន្ធប៉ាតង់ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៨៥
- ច្បាប់ស្តីពីសារពើពន្ធ លេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ មាត្រា ១២៧-១៣៥។

❖ **អនុក្រឹត្យ**

- អនុក្រឹត្យស្តីពី ការតម្លើងចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតិក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨
- អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ស្តីពីការរៀបចំប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣
- អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ស្តីពីការរៀបចំប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ លេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ មាត្រា៦
- អនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម លេខ ១១៤ អនក្រ.បក, ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៥។
- អនុក្រឹត្យស្តីពីការកែសម្រួលអត្រាអករពិសេសលើមុខទំនិញមួយចំនួនលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ និងប្រកាសស្តីពីការណែនាំអនុវត្តការប្រមូលអាករពិសេសលើទំនិញ និងសេវាមួយចំនួន លេខ ១១៣៣ សហវ.ពដ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣។

❖ **ប្រកាស**

- ប្រកាសស្តីពី ពន្ធលើចំណេញមូលធន
- ប្រកាសស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារលេខ ១២៣២ សហវ.ក្រ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០១៧ ប្រការ៧ និងប្រកា៨
- ប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់លេខ ២២៤ សហវ.ពដ.ប្រក ចុះថ្ងៃទី០៥ កក្កដា ឆ្នាំ១៩៩៦
- ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រាលេខ ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ មេសា ឆ្នាំ២០១៧

- ប្រកាសស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់,លេខ១៨២១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០១៥
- ប្រកាសស្តីពីពន្ធលើប្រាក់ចំណូលលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២០
- ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្សលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣
- ប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០
- ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈលេខ ១៧៥ សហវ.ពដ. ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០២
- ប្រកាសស្តីពីការអនុវត្តន៍អាករលើការស្នាក់នៅ លេខ ៣៨០ សហវ.ពដ.ប្រក,ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០០៥
- ប្រកាសស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២០
- ប្រកាសស្តីពីការគ្រប់គ្រងប្រមូលពន្ធលើប្រាក់ឈ្នួលផ្ទះនិងដី,លេខ០២១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៤

❖ **សេចក្តីជូនដំណឹង**

- សេចក្តីជូនដំណឹងស្តីពីការពន្យាកាលបរិច្ឆេទកំណត់ដាក់ឲ្យអនុវត្តពន្ធលើចំណេញមូលធនលេខ២៤០៩៤ អពដ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ

❖ **សៀវភៅច្បាប់**

- សៀវភៅនិតិពន្ធដារទំព័រទី១ សញ្ញាណទូទៅនៃនិតិពន្ធដារ របស់សាស្ត្រាចារ្យ វ៉ែន ឈុនហួត សាកលវិទ្យាល័យឯកទេសនៃកម្ពុជា
- សៀវភៅសារពើពន្ធមុខវិជ្ជានិតិពន្ធដារ របស់លោកគ្រូ គង់ ប៊ុនធី
- សៀវភៅ ស្តីពី ប្រភេទនៃពន្ធ រៀបចំចងក្រងដោយ លោក ឡេ ក្រឹម

❖ **សិក្ខាសាលា**

- បទបង្ហាញស្តីពី ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធនរបស់ប្រទេសមួយចំនួន និងករណីកម្ពុជា
- បទបង្ហាញស្តីពី ពន្ធលើចំណេញមូលធន របស់អគ្គនាយកដ្ឋានពន្ធដារ
- បទបង្ហាញស្តីពីទិដ្ឋភាពទូទៅ នៃច្បាប់ពន្ធដារ និងការអនុវត្តក្នុងឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានពន្ធដារ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦

# បញ្ជីឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០៣.២៥............សហវ.ប្រក

# ប្រកាស
## ស្តីពី
## ពន្ធលើចំណេញមូលធន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងដាក់អនុវត្តពន្ធលើចំណេញមូលធនដែលសម្រេចបានដោយអ្នកជាប់ពន្ធ ស្រប តាមមាត្រា ៧ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅដាក់ចេញនូវវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន ដែល សម្រេចបានដោយអ្នកជាប់ពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធដែលទទួលបានចំណេញមូលធន។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "អ្នកជាប់ពន្ធ" សំដៅដល់ អ្នកជាប់ពន្ធនិវាសនជន ឬអ្នកជាប់ពន្ធអនិវាសនជន ដែលបានលក់ឬផ្ទេរ មូលធនទៅឱ្យបុគ្គលដទៃ។

២- ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់ រូបវន្តបុគ្គលណាម្នាក់ដែលមានលក្ខណវិនិច្ឆ័យចាប់ពីមួយឡើង ទៅក្នុងចំណោមលក្ខណវិនិច្ឆ័យទាំងបីដូចខាងក្រោម÷

- ក- មាននិវាសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មសិទ្ធិឬជួល ឬភតិសន្យា ផ្ទះ អគារ បន្ទប់ជួល អន្តេវាសិកដ្ឋាន។ល។ ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះតែងតែស្នាក់នៅឬកាន់កាប់
- ខ- មានកន្លែងស្នាក់នៅជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរូបភាពជាក់ស្តែងនៃការស្នាក់នៅ ដោយផ្អែកទៅលើកត្តានានា ដូចជា មជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល រយៈពេលស្នាក់នៅ ចរិត នៃការស្នាក់នៅ ទីកន្លែងដែលគ្រួសាររបស់រូបវន្តបុគ្គលនោះស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល ទីកន្លែងដែលរូបវន្តបុគ្គលធ្វើសកម្មភាពសង្គមជាសំខាន់
- គ- មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃក្នុងមួយលើកឬច្រើនលើក ក្នុងរយៈពេល ១២ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅនៅក្នុងព្រះរាជាណាចក្រ កម្ពុជា វត្តមានក្នុងចំណែកណាមួយនៃថ្ងៃត្រូវរាប់ថាជា ១ថ្ងៃពេញ។

ក្នុងករណីដែលមានភាពមិនច្បាស់លាស់ក្នុងការវិនិច្ឆ័យតាមលក្ខខណ្ឌដែលមានចែងក្នុងវាក្យខណ្ឌ ក និង វាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ វត្តមានរបស់រូបវន្តបុគ្គលដែលមានចែងក្នុងវាក្យខណ្ឌ គ គឺជាលក្ខខណ្ឌចុងក្រោយ សម្រាប់កំណត់ភាពជានិវាសនជនរបស់រូបវន្តបុគ្គល។

៣- ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" គឺជារូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន។

៤- ពាក្យ "មូលធន" សំដៅដល់ អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា រូបិយវត្ថុបរទេស។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ ពាក្យ÷

ក- អចលនទ្រព្យ សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើអចលនទ្រព្យ

ខ- ភតិសន្យា សំដៅដល់ ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់និងប្រើប្រាស់អចលនវត្ថុក្នុងរយៈពេលមួយដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬតាមតម្លៃសមមូល។ ភតិសន្យារួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ វៀរលែងតែភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុ និងភតិសន្យាពិសេសដែលមានចែងក្នុងច្បាប់ស្តីពីភតិសន្យាពិសេស

គ- ទ្រព្យវិនិយោគ សំដៅដល់ ភាគហ៊ុន សញ្ញាប័ណ្ណ និងមូលបត្រ ដែលបោះផ្សាយដោយសហគ្រាសឯកជន

ឃ- កេរ្តិ៍ឈ្មោះអាជីវកម្ម សំដៅដល់អាជ្ញាប័ណ្ណ បញ្ជីឈ្មោះអតិថិជន និងឃីហោ

ង- កម្មសិទ្ធិបញ្ញា រួមមាន គតកម្ម ស្នាដៃអក្សរសាស្ត្រនិងសិល្បៈ និមិត្តសញ្ញា រូបភាពនិងគំនូរ ដែលត្រូវបានប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម

ច- រូបិយវត្ថុបរទេស សំដៅដល់រូបិយប័ណ្ណក្រៅពីប្រាក់រៀល។

៥- ពាក្យ "ចំណេញមូលធន" សំដៅដល់ ប្រាក់ចំណូលជាប់ពន្ធដែលបានពីការយកចំណូលពីការលក់ឬផ្ទេរមូលធន ដកការកាត់កងចំណាយដែលអនុញ្ញាត។

## ប្រការ ៥.- ការលើកលែងពន្ធ

ពន្ធលើចំណេញមូលធន ត្រូវបានលើកលែងចំពោះការលក់ឬផ្ទេរ÷

១- ទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋ។

២- ទ្រព្យដែលជាកម្មសិទ្ធិរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃ។

៣- និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធ ដែលបានកាន់កាប់ក្នុងរយៈពេលយ៉ាងតិចប្រាំ (៥) ឆ្នាំមុនពេលលក់ឬផ្ទេរ។ ក្នុងករណីអ្នកជាប់ពន្ធមាននិវាសនដ្ឋានច្រើនជាងមួយ ឬអ្នកជាប់ពន្ធនិងសហព័ទ្ធមាននិវាសនដ្ឋានផ្សេងពីគ្នា និវាសនដ្ឋានតែមួយប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតជានិវាសនដ្ឋានជាគោលដើម។

៤- អចលនទ្រព្យក្នុងវង្វង់ញាតិដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រា វៀរលែងតែការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត រវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ និងរវាងយាយ-តាក្មេកនិងចៅប្រសារ។

៥- ទ្រព្យដែលត្រូវបានលក់ឬផ្ទេរដើម្បីបម្រើប្រយោជន៍សាធារណៈ ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍។

## ប្រការ ៦.- ពេលសម្រេចបានចំណេញមូលធន

សម្រាប់គោលដៅនៃប្រកាសនេះ អ្នកជាប់ពន្ធសម្រេចបានចំណេញមូលធន នៅពេល÷

១- លក់ឬផ្ទេរ ឬបង្កើតឱ្យមានសិទ្ធិគ្រប់គ្រងលើទ្រព្យ ឬ

២- ចុះបញ្ជីសម្រាប់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ទ្រព្យនៅអាជ្ញាធរមានសមត្ថកិច្ច ឬ

៣- ពេលសម្រេចផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ទ្រព្យដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។

## ប្រការ ៧.- ចំណាយដែលអាចកាត់កងបាន

ចំណាយដែលអាចអនុញ្ញាតឱ្យកាត់កងបាន ត្រូវបំពេញនូវលក្ខខណ្ឌទាំងបីដូចខាងក្រោម÷

១- ហេតុការណ៍ដែលបញ្ជាក់អំពីការកើតឡើងនូវបន្ទុក ឬចំណាយ ដែលមានភស្តុតាងអាចត្រួតពិនិត្យបាន

២- លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទិននឹងចំណាយ

៣- មានវិក្កយបត្រ ឬឯកសារភស្តុតាងបញ្ជាក់អំពីចំនួនទឹកប្រាក់ដែលបានចំណាយ។

## ប្រការ ៨.- វិធាននៃការកាត់កងចំណាយ

វិធាននៃការកាត់កងចំណាយ ត្រូវបានកំណត់ដូចខាងក្រោម÷

១- ចំពោះមូលធនជាអចលនទ្រព្យ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យជ្រើសរើសវិធីណាមួយក្នុងចំណោមវិធីទាំងពីរដូចខាងក្រោម÷

ក- វិធីកាត់កងចំណាយតាមការកំណត់÷ ត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងចំណាយ ៨០ ភាគរយនៃប្រាក់ចំណូលដែលទទួលបានពីការលក់ឬផ្ទេរទ្រព្យ

ខ- វិធីកាត់កងតាមចំណាយជាក់ស្តែង÷ ត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងចំណាយដែលបានកើតឡើងជាក់ស្តែង។

២- ចំពោះមូលធនដទៃទៀត អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយ តែតាមវិធីកាត់កងតាមចំណាយជាក់ស្តែងប៉ុណ្ណោះ។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធជ្រើសរើសវិធីកាត់កងតាមចំណាយជាក់ស្តែង ហើយចំណាយដែលបានកើតឡើងជាក់ស្តែងមានចំនួនច្រើនជាងចំណូលពីការលក់ឬផ្ទេរទ្រព្យ ចំនួនលើសមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបង្វិលសង ឬយកទៅកាត់កងចេញពីចំណេញមូលធននៃទ្រព្យដទៃទៀតទេ។

## ប្រការ ៩.- ថ្លៃលក់ និងថ្លៃដើមនៃទ្រព្យ

ដើម្បីគណនាពន្ធលើចំណេញមូលធន ថ្លៃលក់និងថ្លៃដើមនៃទ្រព្យ ត្រូវកំណត់ដូចខាងក្រោម÷

១- ថ្លៃលក់នៃទ្រព្យ ត្រូវគិតតាមតម្លៃលក់ឬផ្ទេរទ្រព្យដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាទិញ-លក់ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធរកឃើញថាថ្លៃលក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាទិញ-លក់ មានតម្លៃទាបជាងតម្លៃទីផ្សារ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ឡើងវិញនូវថ្លៃលក់នៃទ្រព្យ ដោយឈរលើតម្លៃទីផ្សារ ឬតម្លៃដែលកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬតម្លៃដែលកំណត់ដោយគណៈកម្មការវាយតម្លៃទ្រព្យនៃពន្ធលើចំណេញមូលធន។

២- ថ្លៃដើមនៃទ្រព្យរួមមាន ថ្លៃដើមពេលទិញទ្រព្យ និងចំណាយដែលបានកើតឡើងក្នុងពេលទិញឬទទួល កាន់កាប់ លក់ឬផ្ទេរទ្រព្យ ដែលជាអាទិ៍មាន÷

ក- ចំណាយលើសេវាពិគ្រោះយោបល់

ខ- ប្រាក់ពន្ធប្រថាប់ត្រាដែលបានបង់នៅពេលទិញឬទទួលទ្រព្យ

គ- ប្រាក់ពន្ធលើអចលនទ្រព្យ ឬប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលបានបង់

ឃ- ចំណាយលើសេវារដ្ឋបាលសុរិយោដីឬភូមិបាល

ង- ចំណាយលើការផ្សព្វផ្សាយពាណិជ្ជកម្ម

ច- ចំណាយកម្រៃជើងសា

ឆ- ចំណាយលើការវាយតម្លៃទ្រព្យ

ជ- ចំណាយលើសេវារដ្ឋបាលចំពោះការខ្ចីប្រាក់ដើម្បីទិញឬទទួលទ្រព្យ

ឈ- ចំណាយការប្រាក់ចំពោះការខ្ចីប្រាក់ដើម្បីទិញទ្រព្យដែលបានបង់ក្នុងអំឡុងពេលកាន់កាប់ទ្រព្យ

ញ- ចំណាយថែទាំនិងកែលម្អទ្រព្យ

ដ- ចំណាយក្នុងការបង្កើតឬរក្សាការពារនូវសិទ្ធិកាន់កាប់ទ្រព្យ។

**ប្រការ ១០.- អត្រាពន្ធ**

អត្រាពន្ធលើចំណេញមូលធន ត្រូវបានកំណត់តាមអត្រាថេរ ២០%។

**ប្រការ ១១.- ការគណនាចំណេញមូលធន**

អនុលោមតាមប្រការ ៨ នៃប្រកាសនេះ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យជ្រើសរើសវិធីគណនាចំណេញមូលធនណាមួយក្នុងចំណោមវិធីទាំងពីរ ដូចខាងក្រោម÷

១- វិធីកាត់កងចំណាយតាមការកំណត់

**ឧទាហរណ៍ ១១.១**

លោក **ក** បានលក់ផ្ទះមួយល្វែងទៅឱ្យលោក **ខ** ក្នុងតម្លៃ ៨០០ ០០០ ០០០ រៀល។ លោក **ក** មិនបានរក្សាទុកនូវឯកសារចំណាយនានាពាក់ព័ន្ធនឹងផ្ទះល្វែងនោះ។ ដូចនេះ លោក **ក** អាចជ្រើសយកវិធីកាត់កងចំណាយតាមការកំណត់ ដែលត្រូវបានគណនាដូចខាងក្រោម÷

| | |
|---|---|
| ចំណូលពីការលក់ឬផ្ទេរទ្រព្យ | = ៨០០ ០០០ ០០០ រៀល |
| ការកាត់កងចំណាយតាមការកំណត់ | = ៨០% x ចំណូលពីការលក់ឬផ្ទេរទ្រព្យ |
| | = ៨០% x ៨០០ ០០០ ០០០ |
| | = ៦៤០ ០០០ ០០០ រៀល |
| ចំណេញមូលធន | = ចំណូលពីការលក់ឬផ្ទេរទ្រព្យ - ចំណាយតាមការកំណត់ |
| | = ៨០០ ០០០ ០០០ - ៦៤០ ០០០ ០០០ |
| | = ១៦០ ០០០ ០០០ រៀល |

២- វិធីកាត់កងតាមចំណាយជាក់ស្តែង

**ឧទាហរណ៍ ១១.២**

លោក **ក** បានលក់ផ្ទះមួយល្វែងទៅឱ្យលោក **ខ** ក្នុងតម្លៃ ៦០០ ០០០ ០០០ រៀល ដែលបានទិញក្នុងតម្លៃ ៤០០ ០០០ ០០០ រៀល ដោយបានបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនវត្ថុ ១៦ ០០០ ០០០ រៀល បានចំណាយកម្រៃជើងសាសម្រាប់ការលក់ផ្ទះ ២៤ ០០០ ០០០ រៀល និងបានចំណាយជួសជុលកែលម្អផ្ទះ ២០ ០០០ ០០០ រៀល។

លោក ឥ បានរក្សាទុកនូវឯកសារចំណាយនានាពាក់ព័ន្ធនឹងការកាន់កាប់ និងកែលម្អផ្ទះល្វែងនោះ។ ដូចនេះ លោក ឥ អាចជ្រើសយកវិធីកាត់កងតាមចំណាយជាក់ស្តែង ដែលត្រូវបានគណនាដូចខាងក្រោម÷

ចំណូលពីការលក់ឬផ្ទេរទ្រព្យ= ៦០០ ០០០ ០០០

ចំណាយជាក់ស្តែងសរុប = ថ្លៃដើម + ប្រាក់ពន្ធបានបង់ + ចំណាយកម្រៃជើងសា + ចំណាយកែលម្អ

= ៤០០ ០០០ ០០០ + ១៦ ០០០ ០០០ + ២៤ ០០០ ០០០ + ២០ ០០០ ០០០

= ៤៦០ ០០០ ០០០ រៀល

ចំណេញមូលធន = ចំណូលពីការលក់ឬផ្ទេរទ្រព្យ - ចំណាយជាក់ស្តែងសរុប

= ៦០០ ០០០ ០០០ - ៤៦០ ០០០ ០០០

= ១៤០ ០០០ ០០០ រៀល

**ប្រការ ១២.- ការគណនាពន្ធលើចំណេញមូលធន**

ពន្ធលើចំណេញមូលធន ត្រូវបានគណនាដោយយកចំណេញមូលធន គុណនឹងអត្រាពន្ធដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។

**ឧទាហរណ៍ទី ១២.១**

លោក ឥ ជាអ្នកជាប់ពន្ធនិវាសនជន ទទួលបានចំណេញមូលធនពីការលក់ផ្ទះល្វែងចំនួន ៣៤០ ០០០ ០០០ រៀល។

ពន្ធលើចំណេញមូលធន = ចំណេញមូលធន x អត្រាថេរ ២០%

= ៣៤០ ០០០ ០០០ x ២០%

= ៦៨ ០០០ ០០០ រៀល

**ឧទាហរណ៍ទី ១២.២**

លោក ខ ជាអ្នកជាប់ពន្ធអនិវាសនជន ទទួលបានចំណេញមូលធនពីការលក់ភាគហ៊ុនក្នុងក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា ចំនួន ៤០០ ០០០ ០០០ រៀល។

ពន្ធលើចំណេញមូលធន = ចំណេញមូលធន x អត្រាថេរ ២០%

= ៤០០ ០០០ ០០០ x ២០%

= ៨០ ០០០ ០០០ រៀល

**ប្រការ ១៣.- ពន្ធលើចំណេញមូលធនចំពោះទ្រព្យនៅក្រៅព្រះរាជាណាចក្រកម្ពុជា**

ក្នុងករណីដែលអ្នកជាប់ពន្ធនិវាសនជន ទទួលបានចំណេញមូលធនពីទ្រព្យណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងបានបង់ពន្ធលើចំណេញមូលធនតាមច្បាប់ពន្ធដារបរទេសរួចហើយ ប្រសិនបើប្រាក់ពន្ធនៅបរទេសនោះ មានចំនួនតិចជាងប្រាក់ពន្ធដែលគណនាតាមប្រការ ១២ នៃប្រកាសនេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមតែចំនួនលម្អៀងប៉ុណ្ណោះ។

### ប្រការ ១៤.- ការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធ

អ្នកជាប់ពន្ធ ត្រូវដាក់លិខិតប្រកាសពន្ធតាមទម្រង់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងបង់ពន្ធលើចំណេញមូលធន តាមប្រតិបត្តិការនីមួយៗជូនរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេលមិនលើសពី ០៣ខែបន្ទាប់ពីសម្រេចបានចំណេញមូលធនដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ។ ចំពោះទ្រព្យដែលស្ថិតនៅរាជធានីភ្នំពេញ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះទ្រព្យដែលស្ថិតនៅតាមបណ្ដាខេត្ត អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅសាខាពន្ធដារខេត្តដែលទ្រព្យស្ថិតនៅ។

### ប្រការ ១៥.- ឯកសារតម្រូវ

អ្នកជាប់ពន្ធត្រូវផ្ដល់នូវឯកសារពាក់ព័ន្ធ សម្រាប់ការបង់ពន្ធលើចំណេញមូលធន ដូចខាងក្រោម÷

ក- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស

ខ- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ

គ- លិខិតបញ្ជាក់របស់អ្នកជាប់ពន្ធ អំពីការកំណត់និវាសនដ្ឋានជាគោលដើមរបស់ខ្លួន

ឃ- ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ-សង្កាត់ឡើងទៅ ឬឯកសារបញ្ជាក់ការទទួលស្គាល់របស់ស្ថាប័នមានសមត្ថកិច្ច

ង- កិច្ចសន្យាទិញ-លក់ទ្រព្យ ឬកិច្ចសន្យាដោះដូរឬអំណោយ

ច- វិក្កយបត្រទូទាត់ប្រាក់ និងវិក្កយបត្រចំណាយផ្សេងៗដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ

ឆ- ឯកសារដទៃទៀតពាក់ព័ន្ធនឹងការលក់ឬផ្ទេរមូលធន។

### ប្រការ ១៦.- សិទ្ធិក្នុងការត្រួតពិនិត្យ

រដ្ឋបាលសារពើពន្ធមានសិទ្ធិត្រួតពិនិត្យ ដើម្បីធ្វើការកំណត់ឡើងវិញនូវមូលដ្ឋានគិតពន្ធ និងប្រាក់ពន្ធត្រូវបង់ ក្នុងករណីដែលអ្នកជាប់ពន្ធមិនផ្ដល់ឯកសារពាក់ព័ន្ធត្រឹមត្រូវ។

### ប្រការ ១៧.- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មូលធន

រាល់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មូលធនមិនមានលក្ខណៈគតិយុត្តគ្រប់គ្រាន់ទេ ក្នុងករណីដែលមូលធននោះមិនទាន់មានការបញ្ជាក់ពីការបង់ពន្ធលើចំណេញមូលធន។

### ប្រការ ១៨.- ការគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន

ពន្ធលើចំណេញមូលធន ត្រូវចាប់អនុវត្តលើចំណេញមូលធនដែលកើតមានឡើងចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ តទៅ។

**ប្រការ ១៩.- ទោសទណ្ឌ**

អ្នកជាប់ពន្ធត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្ដីពីសារពើពន្ធជាធរមាន ក្នុងករណីមិនបានដាក់លិខិតប្រកាសនិងបង់ពន្ធលើចំណេញមូលធនតាមពេលកំណត់។

**ប្រការ ២០.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ២០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...២៤០៩៤......អពដ

L20200828001 | TD2432

ថ្ងៃព្រហស្បតិ៍ ០៧កើត ខែ កត្ដិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការពន្យារកាលបរិច្ឆេទកំណត់ដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធន

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធនិងសាធារណជនទាំងអស់ ជ្រាបថា យោងតាមលិខិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីសំណើសុំពន្យារពេលការអនុវត្តពន្ធលើចំណេញមូលធន និងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ រាជរដ្ឋាភិបាលបានសម្រេចឱ្យពន្យារកាលបរិច្ឆេទកំណត់ការដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធនរយៈពេល ១ឆ្នាំទៀត រហូតដល់ដំណាច់ឆ្នាំ២០២១ ដើម្បីទុកពេលវេលាគ្រប់គ្រាន់ដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់នូវបទប្បញ្ញត្តិស្ដីពីពន្ធលើចំណេញមូលធន ព្រមទាំងជាការត្រៀមខ្លួនចូលរួមអនុវត្តពន្ធលើចំណេញមូលធននេះឱ្យមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ តទៅ។

សេចក្ដីដូចបានជម្រាបខាងលើ សូមសាធារណជន និងអ្នកជាប់ពន្ធទាំងអស់ ជ្រាបជាព័ត៌មាន។

**អគ្គនាយកដ្ឋានពន្ធដារ**